ការផ្លាស់ប្ដូរមនុស្សក្នុងតំណែងសម្របសម្រួលនោះជាសេចក្ដីសម្រេចចិត្តមួយនាំឲ្យហិនហោច។ ដូចពាក្យស្លោកថា «គ្មាននរណាជាអ្នកទស្សន៍ទាយនៅក្នុងភូមិស្រុកខ្លួនឯងទេ» ពួកសាវៈយេស៊ូក៏មិនសូវទទួលស្គាល់ជម្រៅការងារលោកឪពុក Pierre ប៉ុន្មានដែរ។ គេទើសទើងគាត់ច្រើនណាស់។ បើយើងជាគ្រហស្ថតូចតាចទទួលយកអ្វីដោយក្ដីដឹងគុណហើយ បព្វជិតវិញរើសយកទៅដាក់ខ្លួន ហើយមើលឃើញថាជាការពេបជ្រាយដល់ជីវិតក្រខ្សត់តែមានខ្ទោះរបស់ខ្លួន ឬថាជាការពេបជ្រាយដល់ពួកគេដែលយកព្រះយេស៊ូធ្វើជាគម្រូ តែមានការលំបាកក្នុងការរស់នៅឲ្យដូចព្រះយេស៊ូ។

នៅរវាងឆ្នាំ១៩៩០ មានការផ្លាស់ប្ដូរមួយទៀតនៅទល់ដែន។

នៅចុងឆ្នាំ១៩៨៩ជញ្ជាំងកំពែងក្រុងBerlinដែលរលំទៅនោះបណ្ដាលឲ្យស្ថានភាពលោកយើងនេះរង្គោះរង្គើ ហើយត្រូវរៀបចំតាមបែបថ្មីវិញ។ប្រទេសកម្ពុជានិងជម្រុំអ្នកភៀសខ្លួនខ្មែរដែលធ្លាប់តែជាផាកមួយបង្ហាញពីការប្រឈមមុខដាក់គ្នារវាងកម្លាំងមូលធននិងកម្លាំងកុម្មុយនីស្តនោះក៏ចាប់ផ្ដើមលែងជាទីត្របាញ់ភ្នែកតទៅទៀត។ មកទល់ពេលនោះ ជម្រុំភៀសខ្លួនជាកញ្ចក់តាំងបង្ហាញទំនិញមួយធំនៃបញ្ចឹមប្រទេស។ គ្មានពេលមួយណា ដែលពុំឃើញអ្នកកាសែតឬអ្នកនយោបាយដើរកាត់មុខនោះឡើយ។

ខ្ញុំនៅចាំថាពេលព្រឹកមួយនោះនៅឆ្នាំ១៩៨៦ក្នុងជម្រុំខាវអ៊ីដាងមានគេមកបន្ទប់ស្នាក់ការនៃHandicap International ប្រាប់ឲ្យយើងរៀបចំខ្លួនឈរជាជួរ ដើម្បីឲ្យលោក Henri Kissinger ដើរចាប់ដៃយើងម្នាក់ៗបានឆាប់រហ័សមិនខាតពេល។ បើនិយាយពីឡានដែលដឹកទេសចរមកទាំងហ្វូងៗក៏ដូចគ្នាដែរ គឺមានរបៀបរបបតែមួយ។ ទិដ្ឋភាពដែលនៅចាំមួយទៀតគឺក្រុមអ្នកកាសែត,អ្នកទូរទស្សន៍គ្រប់បែបយ៉ាង ដែលយើងតែងឃើញថា នៅយប់ឡើង តែងដើរតាមផ្សារដើម្បីស្រង់ព័ត៌មានឬដើរតាមជម្រុំ ប្រសិនបើអ្នកនោះមានសំបុត្រអនុញ្ញាត។

នៅជំនាន់នោះ គេមិនដែលគិតថាជម្រុំនៅទល់ដែនមានសារសំខាន់ជានយោបាយយ៉ាងដូចម្ដេចទេ។ គេយល់ជាស្វ័យប្រវត្តិថាការដែលអ្នកភៀសខ្លួនមកដល់ទីនេះមានន័យរួចទៅហើយគឺថាជាន័យនយោបាយ។ រីឯន័យនយោបាយនោះ គឺថាជនភៀសខ្លួនមកទីនេះដើម្បីតស៊ូប្រឆាំងនឹងសត្រូវស្នូរពូជដែលជាយួន។

និយាយមួយម៉ាត់មក គឺជនភៀសខ្លួនជាអ្នកតស៊ូប្រឆាំង។ ប៉ុន្តែចាប់ពីឆ្នាំ១៩៩០មក ជម្រុំចាប់ផ្ដើមអស់សារសំខាន់ក្នុងការឆ្លុះបញ្ចាំងការប្រឈមមុខដាក់គ្នារវាងប្រទេសខាងលិចនិងខាងកើត ដោយសារសង្គ្រាមត្រជាក់ចាប់ផ្ដើមខ្សោយទៅដែរ។ ជម្រុំក្លាយទៅជាទីកក់ជ្រៅមួយ ដើរទៅអាចផុងជើង។ ទស្សនៈនិងការផ្សព្វផ្សាយនៃអង្គការក្រៅរដ្ឋាភិបាលនានាក៏ផ្លាស់ប្ដូរយ៉ាងខ្លាំង។គេលែងនិយាយថាជនភៀសខ្លួនជាអ្នកតស៊ូប្រឆាំងទៀតហើយ តែគេថាអ្នកនោះ ស្ថិតនៅក្រោមការឃាត់ចាប់ខ្លួននៃក្រុមមេដឹកនាំចលនាប្រឆាំង ហើយជាអ្នកភៀសខ្លួនដោយសារក្រីក្រទៅរកលំនៅថ្មី។

ដូច្នេះហើយបានជាពេលដែលគេយកជម្រុំចូលស៊ុបទៅក្នុងដីប្រទេសថៃឡង់ដ៍ទៅ អ្នកទាំងនោះក៏លែងឈរជើងនៅលើទឹកដីមាតុភូមិខ្លួន ហើយឧត្ដមគតិក្នុងការតស៊ូប្រឆាំងដែលមានពីមុនមកក៏អស់ន័យទៅ។ គួរឲ្យព្រឺក្បាលដែរ ការប្ដូរផ្លាស់ក្រឡាប់ចាក់ក្នុងការនិយាយស្ដីនិងការសរសេរនៃអង្គការនានា។ ម្សិលមិញជាបាតដៃ ថ្ងៃនេះជាខ្នងដៃ។

សេរីភាពក្នុងការគិតពិចារណាមានន័យថាដូចម្ដេចដែរ? គេអាចឆ្លើយមកខ្ញុំថាការអះអាងដែលធ្លាប់ឮពីមុនមក ក៏អាចជាអះអាងបន្ទំដែរ គឺថាអ្នកភៀសខ្លួនប្រហែលជាតែងតែស្ថិតក្នុងការចាប់ខ្លួនតាំងតែពីដើមមក។ ខ្ញុំមិនទាស់អ្វីនឹងការឆ្លើយនេះទេ។ ដែលខ្ញុំមិនអស់ចិត្តនោះគឺការផ្លាស់សទៅជាខ្មៅក្នុងការនិយាយអះអាងតែតាមបបូរមាត់ ហើយគ្មានឃើញលទ្ធផលអ្វីជាដុំកំភួនទៅលើស្ថានភាពជម្រុំសោះ។

ខ្ញុំនឹកឃើញសំដីលោកឪពុក Pierre នាពេលមួយនោះ ៖ «គេអាចថា Site 2 ជាទីបាបកម្ម។ មានគេនិយាយនិងសរសេរថាដូច្នេះឯង។ ប៉ុន្តែSite2ក៏ជាទីសណ្ដោសប្រណីនិងជាសោភ័ណដែលមានលើសទីដ៏ទៃទៀតដែរ។ ពិតហើយថាមានការព្រួយបារម្ភ, ចិត្តមិនស្ងប់, កើតទុក្ខ, ឈឺចាប់ពីរឿងកន្លងមក, ខ្វល់ខ្វាយរឿង

អនាគតជាដើមប៉ុន្តែខ្ញុំយល់ថាទីនេះមនុស្សមានឧត្តមភាពជាងនៅទីដទៃ»[5]។ យើងដឹងថាសំដីនេះជាចម្លើយទៅការអះអាងយ៉ាងក្រអឺតក្រទមដែលច្រើនតែចេញមកពីមាត់ក្រុមអ្នកទទួលខុសត្រូវនៃ UNBRO ពោលគឺអង្គភាពនៃអង្គការសហប្រជាជាតិដែលទទួលបន្ទុកគ្រប់គ្រងជម្រុំ។ ចំពោះខ្ញុំវិញ "បាបកម្ម" នោះ កើតមកពីអំពើក្បត់ ដែលធ្វើឲ្យជម្រុំអ្នកភៀសខ្លួនទាំងអម្បាលម៉ានរងគ្រោះ។ គេនឹកស្មានថា គេជួយអ្នកទាំងនោះដោយការពារហើយធ្វើឲ្យដាច់ខ្លួនចេញពីអ្នកតំណាងនានាដែលគេចោទថាពុករលួយ។ នៅក្នុងសំណេរ ដែលមានឈ្មោះថា Un avant poste du progrès លោក Joseph Conrad រៀបរាប់ល្អណាស់ពីទំនោរទូទៅនៃមនុស្សលោកដែលតែងតែភ្ជាប់ខ្លួនឯងទៅនឹងស្ថាប័ននៃមជ្ឈដ្ឋានដែលខ្លួនរស់នៅ ព្រមទាំងទៅអ្នកតំណាងរបស់ខ្លួន ៖ "មនុស្សតិចណាស់ដែលមើលឃើញថាជីវិតខ្លួន, ចរិតខ្លួន, សមត្ថភាពនិងភាពអង់អាចរបស់ខ្លួន គ្រាន់តែជាការឆ្លុះបញ្ចាំងនៃជំនឿជឿជាក់ទៅលើមជ្ឈដ្ឋានរបស់ខ្លួនតែប៉ុណ្ណោះ។ សេចក្តីក្លាហាន, មិនតក់ស្លុត, ទុកចិត្តលើខ្លួនឯង, អារម្មណ៍សព្វបែបយ៉ាង, គោលការណ៍ដែលប្រកាន់យក, គំនិតគ្រប់បែប, រាក់ឬជ្រៅ... ទាំងអស់នេះមិនមែនជាលក្ខណៈពិសេសនៃបុគ្គលម្នាក់ទេ តែគឺចេញមកពីឃ្លាំងរួមនៃមជ្ឈដ្ឋានមួយទាំងមូលដែលជឿលើច្បាប់ទម្លាប់ប្រពៃណីរួមគ្នា, ដែលជឿលើកម្លាំងនៃកងពលគ្រប់គ្រងច្បាប់ទម្លាប់នោះ, ដែលជឿលើជំនឿខ្លួនឯង"។

ទល់ដែននៅទីនេះប្រៀបបីដូចជាផ្ទាំងខ្នះមួយជំផុកទៅដោយប្រវត្តិដែលមនុស្សបានឆ្លងកាត់។ រឿងរ៉ាវនានានៅពីក្រោយនោះ គឺលទ្ធផលនៃមនោគមន៍ផ្តាច់ការយ៉ាងធំមួយនៅសតវត្សទី២០, ប្រវត្តិជូរចត់នៃជនភៀសខ្លួនបូកបញ្ចូលជាមួយស្ថានភាពចម្លែកមួយកើតឡើងដោយការគ្រប់គ្រងនៃអង្គការសហប្រជាជាតិ ដែលមានជំនួយមនុស្សធម៌នៅក្នុងនោះ។ ចំពោះខ្ញុំ ពេលនោះជាសម័យកាលមួយដែលធ្វើឲ្យខ្ញុំចោទសួរខ្លួនឯងនិងពិចារណាមិនអស់មិនហើយថា សេរីភាពក្នុងការគិតនោះរឹងមាំដល់ត្រឹមណា ថាក្នុងចិត្តស្មោះសដែលចង់ជួយមនុស្ស តើមានអ្វីដែលហៅថាក្បត់បានឬអត់?

យើងត្រូវចាំជានិច្ចថា គ្មានអ្វីមួយដែលជាប្រក្រតីឬធម្មតាទេនៅក្នុងស្ថានភាពជនភៀសខ្លួន។

ទីមួយគឺស្ថានភាពជាជនភៀសខ្លួននោះតែម្តង ដ្បិតអ្នកនោះអស់អ្វីៗពីខ្លួនរលីង រាប់តាំងពីទ្រព្យធនឡើងទៅ ហើយមកនៅក្រោមទម្ងន់នៃក្រុមអ្នកមានអំណាចផ្សេងៗដែលត្រួតលើគ្នាពីមួយទៅមួយ។ នៅលើគេបង្អស់នោះគឺអង្គភាពដែលមានលក្ខណៈជាទ័ពថៃដែលតែងតែធ្វើយ៉ាងណាឲ្យអ្នកទាំងនេះស្ថិតក្នុងកណ្តាប់ដៃខ្លួនទាំងស្រុង។ បន្ទាប់មកគឺអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលនានាដែល UNBRO ជួលឲ្យបំពេញសេវាផ្សេងៗក្នុងវិស័យពេទ្យ, អនាម័យ, ម្ហូបអាហារនិងស្បៀងជាដើម។ អ្នកកាន់កាប់អង្គការក្រៅរដ្ឋាភិបាលទាំងនេះជាជនបរទេសនៅក្រៅស្រុកមួយរយៈ ហើយដែលមាននាទីអនុវត្តកម្មវិធីការងារ។ ស្របជាមួយគ្នានោះមានអាជ្ញាធរខ្មែរដែលសហការជាមួយ ហើយដែលមើលគ្រប់គ្រង

[5] កំណត់អ្នកនិពន្ធ ៖ ពាក្យពេចន៍នៃលោកឪពុក Pierre ទាំងប៉ុន្មានក្នុងអត្ថបទនេះ សុទ្ធតែស្រង់ចេញពីភាពយន្ត Ombre & Lumière ទាំងអស់។

ជីវិតប្រចាំថ្ងៃ។

ក្រៅពីនេះស្ថានការណ៍មិនខុសពីទីក្រុងនានាទេ គឺថាតែងតែមានក្រុមមនុស្សដែលឆ្លៀតប្រើប្រាស់អាវុធដើម្បីគម្រាមឲ្យគេធ្វើតាមខ្លួន។ ពួកសៀមបានហាមឃាត់មិនឲ្យមានផ្សារនៅក្នុងជម្រុំ ប៉ុន្តែនៅតែមានផ្សារងងឹតដែលកើតរីកឡើង ហើយដែលបង្កើតឲ្យមានការទិញដូរទំនិញផ្សេងៗ។ ឧទាហរណ៍គ្រាប់បែកដៃមួយមានតម្លៃត្រឹមតែ២០បាត ( រវាង០,៧០អឺរ៉ូ)។ការឈ្នានពាននិងហិង្សាផ្សេងៗក៏កើតមានឡើងញឹកញាប់។ នៅឆ្នាំ១៩៩១ សិស្សរបស់ខ្ញុំម្នាក់ត្រូវរបួសដោយអំបែងគ្រាប់បែកដៃមួយ ដែលផ្ទុះឡើងនៅពេលគេដើរតាមច្រកផ្លូវតូចនៅជិតរោងទស្សនីយដ្ឋានមួយ។សិស្សនោះរបួសនៅត្រង់សរសៃនឹងខួរឆ្អឹងចុះពីក្បាលមកបណ្តាលឲ្យខ្វិនរហូត។

ស្ថានភាពមិនប្រក្រតីរបៀបនេះធ្វើឲ្យអ្វីៗមានដំណើរការមិនត្រង់ផ្លូវហើយបើពុំប្រយ័ត្នទេក៏អាចទៅជារៀចរេរកាន់តែខ្លាំង។ ជនដែលគេពុំដឹងថាបានទទួលអាជ្ញាសឹកមកពីណាផង ក៏ស្រាប់តែមកត្រួតកៀបសង្កត់លើអ្នកឯទៀត ដែលរសាត់អណ្តែតមកដល់ទីនេះដោយអកុសល។ ហេតុនេះការបែងញែកឲ្យដាច់ពីគ្នារវាង “យើង” និង “គេ” ក៏លេចចេញឡើងកាន់តែច្បាស់។ បើនិយាយតាមលក្ខណៈវិនិច្ឆ័យនៃអង្គការក្រៅរដ្ឋាភិបាល គឺជនភៀសខ្លួនគ្មានសមត្ថភាព។ រឿងហេតុកំប៉ិកកំប៉ុក ដូចជាការលួចសម្ភារៈអ្វីបន្តិចបន្តួច, ការសុំជំនួយផ្ទាល់ខ្លួនច្រើនបែបយ៉ាងជាដើម ធ្វើឲ្យមានការពោលពាក្យដែលពុំសុក្រិត។ ហើយយើងគួរកុំភ្លេចពីចិត្តដែលបារម្ភពុំស្ងប់នៃអ្នកភៀសខ្លួនដែលបង្ករឡើងដោយការបាត់បង់ទ្រព្យសម្បត្តិនិងអ្វីៗទៀតទាំងអស់មកនៅក្រោមការត្រួតត្រានៃបរទេសដែលមានអំណាច។ ចិត្តបារម្ភនេះពុំងាយស្ងប់បាន ព្រោះអ្នកភៀសខ្លួនមកដល់ទីនេះខ្វល់ទៅដោគវាសនានៃអ្នកមិនដែលមិនបានចេញមកផុតដូចខ្លួន។

ហេតុច្រើនបែបយ៉ាងផ្សេងៗគ្នានេះ បើយកមកគួបគ្នាទើបអាចយល់ថាបរទេសដែលបម្រើការនៅតាមអង្គការក្រៅរដ្ឋាភិបាលច្រើនតែទប់ខ្លួនឲ្យនៅដាច់ពីអ្នកភៀសខ្លួន ហើយមិនទៅលាយឡំនឹងអ្នកទាំងនោះទេហាក់ដូចជាខ្លាច “ឆ្លង” ជំងឺអ្វីមួយដូច្នោះ។ ខ្សែបន្ទាត់ញែកឲ្យមនុស្សពីរក្រុមដាច់ពីគ្នានេះ លោកឪពុក Pierre លុបផ្តាច់ចោលមិនឲ្យមានឡើយទោះជាក្នុងទេសកាលអ្វីណាមួយក៏ដោយ។ ខ្ញុំអាចនិយាយថានេះជា “គោលការណ៍” ដែលគាត់ប្រកាន់យក។ ខ្ញុំហ៊ានថាគាត់ជាព្រះអរហន្ត[6] ពិតប្រាកដដូចដែលមនុស្សស្រម៉ៃថាមានពោលគឺមិនមែនអរហន្តដែលគណអធិបតីបព្វជិតប្រកាសក្នុងបំណងយុទ្ធសាស្ត្រនយោបាយឬសាសនាឡើយ។

បំបាត់ចោលនូវរបាដែលញែកជនភៀសខ្លួនឲ្យដាច់ចេញពីយើងពុំមែនមានន័យថាលង់ខ្លួនទៅក្នុងការស្រណោកស្រណោះបោកខ្លួនបោកប្រាណឡើយ។ គឺមានន័យថាសាមគ្គីជិតស្និត រួមសុខរួមទុក្ខជាមួយអ្នកទាំងនោះ តែមិនរលាយចូលគ្នាលែងដឹងតួនាទីរៀងៗខ្លួននោះទេ។ ក្នុងគំនិតលោកឪពុក Pierre គឺគ្មានការច្រលូកច្រឡំរបៀបនេះទាល់តែសោះ។

---

[6] កំណត់អ្នកប្រែ ៖ ប្រែនេះមិនចំទេ ព្រោះគំនិតដើមស្ថិតនៅក្នុងបរិបទសាសនាយេស៊ូ ឯពាក្យ “អរហន្ត” វិញសំដៅទៅអ្នកបានត្រាស់ក្នុងព្រះពុទ្ធសាសនា។

# ម្ចាស់ការ

ខ្ញុំនៅតែឆ្ងល់ថាហេតុអ្វីបានជាព្រះអរហន្តទាំងឡាយអាចនៅអែបជាប់នឹងយើងបានដោយមិនច្របូកច្របល់នឹងយើង? នេះប្រហែលជាព្រះអង្គទាំងនោះមកដល់"ឋាន"មួយលើកម្រិតដែលចិត្តវិភាគវិទ្យាអាចពន្យល់បាន។ កម្រិតនោះថាភ្លឺថែសក៏បាន ថាប្រកបដោយអាថ៌កំបាំងក៏បាន។ ពិបាកនិយាយណាស់ ព្រោះហាក់ដូចជានៅខ្ពស់ ហើយលយចេញមកមើលឃើញអ្វីនៅក្រោមទាំងអស់។

រាល់ពេលដែលគាត់និយាយពីជនភៀសខ្លួន លោកឪពុកតែងតែសង្កត់ទៅលើសោភ័ណ, ឧត្តមភាពនិងបុព្វហេតុ៖ "បើចង់និយាយពីអ្នកទាំងនោះចូរអ្នកចង្អុលបង្ហាញពីឧត្តមភាពនិងសេចក្ដីថ្លៃថ្នូររបស់គេមិនមែននិយាយពីភាពក្រីក្រលំបាកតោកយ៉ាកឡើយ"។ បើចង់ជួយគេមែនត្រូវជួយក្នុងការគោរព,ក្នុងការស្រឡាញ់។ បើពុំដូច្នោះទេ សូមកុំធ្វើអ្វីទាំងអស់! បើគ្មានការគោរព, គ្មានមេត្រីយ៍, គឺគ្មានប្រយោជន៍អ្វីទាំងអស់ ផ្ទុយទៅវិញអ្នកទាំងនោះឯងដែលនឹងផ្ដល់ប្រយោជន៍ដល់អ្នក... អ្នកនឹងឃើញថាជនភៀសខ្លួនជានរណា? អ្នកនឹងឃើញសោភ័ណភាព, សេចក្ដីថ្លៃថ្នូររបស់គេ។ បើមើលឃើញតែភាពក្រីក្ររហេមរហាមនៅខាងក្រៅនោះគឺចូលក្នុងឥរិយាបទអ្នកមានទ្រព្យនិងពួកអាណានិគមហើយ។ កុំភ្លេចពីសោភ័ណនៃអ្វីមួយ ឬមនុស្សណាម្នាក់។ បើពុំដូច្នោះទេ ខួរយើងច្បាស់ជាផ្អូម! មនុស្សម្នាក់ជាកាព្យមួយ"។

"ឥរិយាបថពួកអាណានិគម" ៖ នេះជាចំណុចដែលត្រូវយកមកគិត ព្រោះខ្ញុំយល់ថាអង្គការក្រៅរដ្ឋាភិបាលមួយភាគធំឈរលើឥរិយាបទនេះឯង។ គ្មានអ្វីគួរឲ្យឆ្ងល់ទេ! គ្រាន់តែយករបាមួយមកបញ្ឈរចែកព្រំដែនមនុស្សញែកឲ្យដាច់គ្នារវាង "គេ" និង "យើង" ទៅក៏នឹងយល់ហើយ។ គ្រប់គ្នាតែងតែធ្វើយ៉ាងដូច្នេះ! ដូចខ្ញុំនិយាយមុននេះមកហើយថា របានេះងាយនឹងឈរឡើងខ្លាំងណាស់ ឲ្យតែភ្លេចខ្លួនបន្តិចគឺនឹងឃើញវានៅពីមុខយើងជ្រងោ។ គប្បីយើងចាំរឿងនេះជានិច្ច បើយើងមានបំណងចង់រៀបចំអភិវឌ្ឍន៍អ្វីមួយ ព្រោះយើងច្រើនតែឃើញថាកាលណាអង្គការណាចប់កម្មវិធីខ្លួន ហើយប្រគល់ទៅឲ្យអាជ្ញាធរដែលជាដៃគូរនោះទៅទៀត កម្មវិធីនោះរលំដួលគ្រាំង។ បើអាជ្ញាធរនោះមិនអាចរៀបចំខ្លួនជាម្ចាស់ការទេ គ្មានអ្វីនឹងគង់វង្សហើយទៅមុខបានជាដាច់ខាត។ មានតែឥរិយាបទគោរពប៉ុណ្ណោះ ទើបអាចឲ្យអ្នកម្ខាងទៀតដែលខ្សត់ខ្សោយក្លាយជាម្ចាស់ការបាន។

ការរំលឹកខាងលើនេះមិនមែននៅតែលើបបូរមាត់នោះទេ ហើយក៏មិនសំដៅចំពោះតែទៅក្រុមការងារលោកឪពុកប៉ុណ្ណោះដែរ។ នៅរាល់កិច្ចជំនុំដែលរៀបចំឡើងដោយ UNBRO គ្មានពេលណាមួយឡើយដែលគេអញ្ជើញលោកឪពុកទៅហើយ ទោះជានៅជម្រុំក្ដី, នៅភោជនីយដ្ឋានតាមផ្សារនៅពេលយប់ក្ដី, ពេលណាទីណាផ្សេងទៀតក្ដី... ដែលគេមិនឮពាក្យរលឹកនេះ។ បើជាមួយក្រុមការងារគាត់ផង គឺគាត់យកចិត្តទុកដាក់នូវរាល់អ្វីទាំងអស់។ គាត់ហាមយើងមិនឲ្យប្រើឡានក្នុងជម្រុំទេ យើងត្រូវដើរឬជិះកង់ គឺថាមិនឲ្យបញ្ចេញអ្វីឲ្យឃើញថានៅខ្ពស់ជាងជនភៀសខ្លួនឡើយ។

ដោយសារជួបជាមួយលោកឪពុកដូច្នេះហើយ បានជាខ្ញុំក៏ខិតខំយកចិត្តទុកដាក់និងការងារ, ត្រិះរិះរកយល់ពីបុព្វហេតុនៃជនភៀសខ្លួនដែលក្លាយជាអ្នកជិតស្និតនឹងខ្ញុំ ពោលគឺកូនសិស្សរបស់ខ្ញុំ។

តាមយោបល់ខ្ញុំ ជំងឺធំបំផុតដែលញាំញីជនភៀសខ្លួន គឺការបាត់បង់ទំនុកចិត្ត ៖ ទំនុកចិត្តលើជីវិត,

ទំនុកចិត្តលើគេដ៏ទៃ, ទំនុកចិត្តលើខ្លួនឯង។ បើអស់ទំនុកចិត្តហើយ តើនឹងអាចធ្វើអ្វីកើត?

រឿងនេះវាត្រូវតែដូច្នេះឯង គ្មានអ្វីគួរឲ្យឆ្ងល់ឡើយ!

ពេលដែលទៅដល់ជម្រុំនានានៅឆ្នាំ១៩៧៩និងដើមឆ្នាំ១៩៨០នោះ គឺអ្នកទាំងនោះបានភៀសខ្លួនរួចពីរបបខ្មែរក្រហមប្រល័យជីវិត៤ឆ្នាំ ព្រមទាំងការអុកឡុករបស់យួនដែលទើបនឹងចាប់ផ្តើមឡើង។ ពេលមកដល់ទល់ដែននោះ គឺថាមានតែសម្បកខ្លួន, ស្បែកដណ្តប់ឆ្អឹង, ស្លៀកពាក់ខ្មៅ, ឃើញឈរជាប់ដីមែន តែព្រលឹងមិននៅនឹងរូបឡើយ។ គ្រាន់តែដឹងថាខ្លួនមកដល់ទល់ដែនហើយ ក៏ដួលព្រួសទៅដី។ បន្ទាប់មកទៀតគឺពេលប៉ុន្មានឆ្នាំដែលនៅក្នុងជម្រុំហើយដែលអ្នកទាំងនោះខំរៀបចំខ្លួនដោយផ្អែកលើសេចក្តីសង្ឃឹម។ គេជឿថាគេអាចនឹងនាំសន្តិភាពនិងឯករាជ្យឲ្យប្រទេសវិញ។ពេលវេលាចេះតែកន្លងទៅគេឃើញថាបរាជ័យផ្ទួរទ័ពកើតឡើងបន្តបន្ទាប់ ក្រោយពីបរាជ័យផ្ទួរទូត។ សេចក្តីសង្ឃឹមក៏ថយចុះម្តងបន្តិចៗ។ ទីបំផុតទៅ កូនដីមួយដុំនៃមាតុភូមិនោះក៏ផុតពីខ្លួនទៅទៀត ដ្បិតកងកម្លាំងតស៊ូខ្មែរទទួលបរាជ័យពេញទីនៅឆ្នាំ១៩៨៥ហើយជម្រុំក៏រំកិលចូលទឹកដី ប្រទេសថៃឡង់ជាស្ថាពរ។ ដូចលោកឪពុកធ្លាប់និយាយដែរ "តាំងពីពេលនោះមកជម្រុំដែលធ្លាប់តែជាជម្រុំតស៊ូប្រឆាំង ក៏ក្លាយទៅជាមហាជម្រុំជនភៀសខ្លួនមួយ"។ ពីមុននោះ នៅរដូវវស្សាអ្នកភៀសខ្លួនរស់នៅលើដីមាតុភូមិខ្លួន ព្រោះរថក្រោះទ័ពយួនមិនអាចវាយសម្រុកបានទេ។ ទាល់តែដល់រដូវប្រាំងទើបរំកិលចូលមកដីសៀម ដោយសាររដូវនេះក្រុមតស៊ូមិនអាចសម្រុកចូលក្នុងបាន។ ក្រោយពីឆ្នាំ១៩៨៥មកជម្រុំនៅមួយកន្លែងលែងចេញពីដីប្រទេសថៃឡង់ដ៏វែងសម្លាធមកលើអ្នកភៀសខ្លួនក៏កាន់តែខ្លាំងឡើងៗ។ ហេតុនេះនរណាអាចមានសង្ឃឹមអ្វីទៀត ក្រៅពីវិរបុរសនិងដើងឆើតក្មេងក្អាងមួយភាគតូច ដែលចំនួនកាន់តែហោចទៅៗ នៅពេលដែលអ្វីៗក៏រលំគ្រេងបន្តបន្ទាប់គ្នា។

ក្នុងទេសកាលនេះហើយ ដែលខ្ញុំចាប់ផ្តើមធ្វើការនៅជម្រុំអ្នកភៀសខ្លួន។ មុនដំបូងនាឆ្នាំ១៩៨៥ នៅខាវអ៊ីដាង ដែលជាជម្រុំអ្នកភៀសខ្លួន "ស្របច្បាប់"។ មុននោះបន្តិចការប្រយុទ្ធគ្នាបានប៉ះពាល់ទៅលើជម្រុំនៅទល់ដែន។ បន្ទាប់មក នៅឆ្នាំ១៩៨៦ ខ្ញុំមករួមការងារក្នុងក្រុមលោកឪពុក Pierre ក្នុងនាទីជាគ្រូបង្រៀនគំនូរដល់ក្មេង នៅជម្រុំធំជាងគេបង្អស់នៅទល់ដែន ហៅថា Site 2។ ពេលនោះអ្នកភៀសខ្លួនអស់សង្ឃឹមមែនទែនហើយ។

នៅជំនាន់នោះ គំនិតថាបើកបង្រៀនមុខវិជ្ជាគំនូរជាការចម្លែកណាស់ (សូម្បីតែខ្ញុំក៏ភ្ញាក់នឹងខ្លួនឯងដែរ ព្រោះខ្ញុំគិតថាមានអ្វីៗច្រើនដែលត្រូវទុកជាអទិភាព)។ លោកឪពុក Pierre ពុំគិតថាដូច្នោះទេ។ ចំពោះគាត់ទោះជាក្នុងទេសកាលដ៏លំបាកយ៉ាងណាក៏ដោយមិនមែនមានតែបាយទេដែលមនុស្សត្រូវការ។និយាយឲ្យពិតទៅ អ្វីដែលមិនមែនជា "តម្រូវការចាំបាច់" នេះឯងហើយ ដែលគាត់គិតថាត្រូវធ្វើ។ ដោយមានលោកឪពុក John Bingham ដែលជាបព្វជិតក្រុមសាវៈយេស៊ូម្នាក់ទៀតជួយគាំទ្រផង គាត់ទាមទារឲ្យអាជ្ញាធរសៀមនិងអ្នកតំណាងអង្គការសហប្រជាជាតិ (ដែលតែងតែយកចិត្តសៀម ហើយមិនសូវហ៊ានរឹងទទឹង) បង្កើតកម្មវិធីបង្រៀនកម្រឹតមធ្យមសិក្សា ហើយរហូតដល់ឧត្តមសិក្សាទៀតផង។ ដោយយកលេសថាអ្នកភៀសខ្លួនគ្រាន់តែនៅទីនេះមួយរយៈប៉ុណ្ណោះ ពួកសៀមមិនឲ្យបើកបង្រៀនវិជ្ជាអ្វីសម្រាប់អនាគតទាំងអស់។ ពួកនោះ

អនុញ្ញាតឲ្យរៀនតែត្រឹមបឋមសិក្សា ដោយអល់ឯកក្នុងចិត្តផង។ បើមធ្យមសិក្សាគឺមិនឲ្យមានទេ។ ទោះជាយ៉ាងណាក្តីបព្វជិតទាំងពីរមិនព្រមថយឡើយ។គាត់នៅតែលើកកម្មវិធីសិក្សានោះថ្វីត្បិតតែក្រៅផ្លូវការ ហើយមិនទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ព្រមទាំងទទួលការគម្រាមថានឹងបិទពីសំណាក់យោធាសៀម។

ខ្ញុំក៏ចាប់ផ្តើមនាំសិស្សកសាងការយល់គ្នាទៅវិញទៅមកម្តងបន្តិចៗ ដោយផ្អែកលើការស្តាបស្ទង់នឹងការថ្លឹងថ្លែង ពោលគឺពុំមានក្បួនច្បាប់អ្វីជាមាគ៌ាឡើយ។ ខ្ញុំខំធ្វើយ៉ាងណាឲ្យខ្លួនខ្ញុំទៅជាបង្គោលមួយអាចឲ្យសិស្សតោងចាប់បាន។ ខ្ញុំគិតនោះត្រូវ ព្រោះមិនយូរប៉ុន្មានលទ្ធផលបានដូចស្មានមែន។ រៀនស្ទើរតែពុំទាន់បានមួយឆ្នាំផង គំនូររបស់គេមានលក្ខណៈជាសិល្បៈពិតប្រាកដ។ ជាបច្ចេកទេសក៏ត្រឹមត្រូវជាន័យក៏វែងឆ្ងាយ។ ខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង មិននឹកស្មានថាបានផលប្រសើរយ៉ាងនេះសោះ។ សិស្សទាំងនោះហាក់ដូចជាយកការគូរគំនូរមកប្រើជាឧបករណ៍កសាងខ្លួនឯង។ អ្នកខ្លះផ្លាស់ប្តូរអាកប្បកិរិយានិងចិត្តទាំងស្រុង គឺថាកាលទើបនឹងចូលរៀននោះមករៀនដោយវិញ្ញាណនៅទីដទៃ, ញ៉ាំញីដោយទុក្ខ ហើយបន្តិចម្តងៗប្រែជាស្រស់ថ្លា, កែប្រែខ្លួន, មានឆន្ទៈយកឈ្នះកម្លាំងបាបកម្ម។ លទ្ធផលល្អនេះ ក៏កាន់តែរឹងប៉ឹងពីមួយឆ្នាំទៅមួយឆ្នាំ ហើយក្រុមសិស្សក៏មានសន្ទុះរឹងមាំរៀងតទៅ។

ចំណុចមួយទៀតដែលខ្ញុំយល់ថាសំខាន់ គឺត្រូវធ្វើយ៉ាងណាកុំឲ្យសិស្សទាំងនោះធ្លាក់ទៅក្នុងគំនិតថាខ្លួនជាអ្នករងគ្រោះដូចមុនទៀត។ត្រូវធ្វើយ៉ាងណាឲ្យគេមានទំនុកចិត្តរឹងមាំលើខ្លួនឯង,សម្លឹងមើលទៅអនាគតយ៉ាងក្លាហាន។ ពាក្យពេចន៍របស់ Joseph Conrad ដែលខ្ញុំនិយាយពីមុននេះ ជាចន្លុះបំភ្លឺឲ្យយល់ពីដំណើរនៃសិស្សក្មេងៗទាំងនោះ។ពិតហើយថាអ្នកទាំងនេះជាអ្នករងគ្រោះ តែស្ថានភាពគេពិសេសម្យ៉ាងត្រង់ថាគេនៅក្មេង។ ដូចជាកូនក្មេងទាំងអស់នៅគ្រប់ទិសទីដែរ គឺគេពុំសូវគិតថាគេរងគ្រោះអ្វីឡើយ។ តាមរយៈគំនូរដែលជាមធ្យោបាយបញ្ចេញគំនិតមកក្រៅពិតប្រាកដ គេក៏ក្លាយទៅជាសាក្សីផង និងជាអ្នកនាំពាក្យផង។និយាយនេះមិនសម្រាប់តែផ្ទាល់ខ្លួនគេទេ គឺសម្រាប់សហគមន៍គេទាំងមូលដែរ។ គេលែងជាអ្នករងគ្រោះទៀតហើយ គឺគេជាម្ចាស់ការខ្លួនឯងយ៉ាងពេញលេញ។ ក្រោយពីបាត់បង់អ្វីៗគ្រប់បែបយ៉ាង គេមិនត្រឹមតែអាចរស់ដោយពឹងផ្អែកលើសង្គមខ្លួនឯងទេ គឺគេពឹងផ្អែកលើខ្លួនឯងផ្ទាល់តែម្តង។ ដូចតែក្មេងទូទៅលើលោកដែរ ការប្រឹងប្រែងប្រយុទ្ធទល់នឹងព្រឹត្តការណ៍ផ្សេងៗនៃជីវិតផង ទល់នឹងខ្លួនឯងផងនោះហើយ ដែលធ្វើឲ្យគេក្លាយជា “អ្នកជា”។នៅពេលដែលគេបិទជម្រុំនៅឆ្នាំ១៩៩២-៩៣ដោយសារទីបំផុតទៅគេប្រកាសសន្ធិសញ្ញាសន្តិភាព ជនភៀសខ្លួនតិចណាស់ដែលរីករាយចិត្តក្នុងការត្រឡប់ចូលស្រុកវិញ ព្រោះគេដឹងថាសន្តិភាពដែលគ្មានតម្លៃប៉ុន្មាននេះ បានឡើងដោយមានសម្ពាធពីអន្តរជាតិ ពោលគឺមិនបានមកដោយការតស៊ូរបស់គេឡើយ។ គេដឹងថាប្រទេសខ្លួនឯងនោះនឹងមិនយកចិត្តទុកដាក់នឹងគេហើយនឹងមិនខ្វល់ខ្វាយអំពីធនធានដែលគេបានបាត់បង់អស់រលីងពីខ្លួនទេ។ គ្មានអ្វីគួរឲ្យឆ្ងល់ឡើយ នៅពេលដែលអង្គការសហប្រជាជាតិគ្រោងថានឹងចែកដីឲ្យគ្រួសារនិមួយៗរស់នៅចិញ្ចឹមជីវិតសាជាថ្មីនោះ គម្រោងមិនបានប៉ុន្មានក៏រលាយខ្យល់ ត្បិតដីដែលអាជ្ញាធរខ្មែរលក់ឲ្យចែកនោះ គឺពោរពេញទៅដោយគ្រាប់មីន។ ដូច្នេះនៅសល់ដំណោះស្រាយតែមួយគត់ គឺជួយលុយ៥០ដុល្លារដល់មនុស្សពេញវ័យ នឹង២៥ដុល្លារដល់ក្មេងម្នាក់ៗ ដើម្បីឲ្យត្រឡប់ទៅស្រុកដែលគេ

បានចាកចេញមកតាំងពី១២-១៣ឆ្នាំមុននោះម៉្លេះ។នៅពេលជម្រុំបិទអស់ហើយ យើងបាននាំជនដែលពិការធ្ងន់ធ្ងរត្រឡប់មកកម្ពុជាវិញតាមការរៀបចំរបស់UNBRO និងកាកបាទក្រហមអន្តរជាតិ។លោកឪពុកក៏មកតាមជាមួយក្រុមនោះដែរ។ ខ្ញុំនៅចាំមិនភ្លេចអំពីការភ្ញាក់ផ្អើលនៃអ្នកតំណាងមន្ទីរពេទ្យបាត់ដំបងដែលទទួលបន្ទុកទទួលអ្នកពិការទាំងនោះ។ នៅពេលដែលគេសួរថា មានកម្មវិធីអ្វីខ្លះដើម្បីសម្រួលឲ្យជនពិការទៅជួបជុំគ្រួសារវិញ ចម្លើយដែលឮមកគឺ "នៅកម្ពុជាឯនេះ ជនពិការមិនអាចរស់នៅតទៅទៀតទេ" ( ហើយខ្ញុំបានឃើញអ្នកពិការ "ទៅ" ម្តងមួយៗដូច្នេះមែន គ្រាន់តែយូរនិងឆាប់ តែគ្មានរណាគេចផុត)។

ក្រោយពីនោះមកខ្ញុំបែកចេញពីឡានដឹកជញ្ជូនអ្នកពិការ ដើម្បីទៅរកជួបសិស្សរបស់ខ្ញុំឲ្យបានច្រើនគ្នា។អ្នកខ្លះស្ថិតនៅជម្រុំជំណាក់[7] ក្នុងដីខ្មែរនៅឡើយ គឺជម្រុំឲ្យស្នាក់មួយរយៈ មុននឹងបញ្ជូនទៅពិភពមួយទៀតដែលពុំស្គាល់។ជនភៀសខ្លួនស្នាក់នៅទីនេះរវាងមួយទៅពីរសប្តាហ៍ ហើយក្នុងរយៈពេលនេះឯងដែលគេអាចស៊ើបសួរដំណឹងរកជួបគ្រួសារឬក៏រៀបចំផែនការផ្សេងៗសម្រាប់រស់តទៅមុខ។ ផុតពីបាត់ដំបងទៅ ខ្ញុំបន្តដំណើរទៅដល់ទល់ដែនវៀតណាមនៅខាងត្បូងប្រទេសកម្ពុជា។អ្វីដែលខ្ញុំធ្លាប់គិតស្មានពីមុនមកគឺកើតមានមែនពិត។ ការរៀបចំឲ្យអ្នកភៀសខ្លួនមករស់នៅក្នុងប្រទេសវិញជាការឆ្លងកាត់មួយលំបាកក្រៃលែង ហើយអ្នកខ្លះឆ្លងមិនទាំងបានផង។

ឥឡូវនេះពេលវេលាមួយវែងកន្លងទៅហើយ ដែលធ្វើឲ្យយើងមើលឃើញថា អ្នកដែលមានជោគជ័យក្នុងការរស់នៅមាតុភូមិកំណើតវិញ គឺច្រើនតែអ្នកដែលបានឆ្លងកាត់កម្មវិធីបណ្តុះបណ្តាលដែលលោកឪពុក Pierre និងលោកឪពុកBingham បានរៀបចំពីមុននោះ។ការអប់រំសិក្សាជាអាវុធសំខាន់បំផុតសម្រាប់បើកឆាកជីវិតថ្មី។ មានតែអាវុធនេះហើយដែលជួយឲ្យឈ្នះឧបសគ្គនៅក្នុងជីវិតតែលតោល១៣ឆ្នាំនៅក្នុងជម្រុំ។ អ្នកខ្លះទទួលតួនាទីផ្សេងៗនៅតាមអង្គការក្រៅរដ្ឋាភិបាល ខ្លះទៀតនៅក្នុងសហគ្រាសក្នុងស្រុក។ ជោគជ័យក្នុងជីវិតគេជារង្វាន់ទទួលស្គាល់ដោយចក្ខុវិស័យធំធេងនៃបព្វជិតសារៈព្រះយេស៊ូទាំងពីរនាក់ ដែលខំពុះពារទល់ជាមួយ UNBRO និងអាជ្ញាធរសៀម។

ក្នុងដំណើរឆ្លងកាត់របស់ខ្ញុំនៅកម្ពុជា ទោះដល់ទីណាក៏ខ្ញុំផ្តាំផ្ញើពាក្យទៅគ្នីគ្នាថាខ្ញុំមានគម្រោងតម្លើងមណ្ឌលសិល្បៈមួយនៅបាត់ដំបង ហើយអតីតកូនសិស្សខ្ញុំណាដែលមានចិត្តចង់ គឺអាចមកធ្វើការជួបជុំគ្នា។ នៅប្រទេសកម្ពុជា ការប្រាប់គ្នាពីមាត់មួយទៅមាត់មួយមានប្រសិទ្ធភាពជាងប្រៃសណីយ៍ឆ្ងាយណាស់។ ដូច្នេះ ហើយបានជាកូនសិស្សខ្ញុំពីមុននោះមកជាបន្តបន្ទាប់គ្នាដល់ផ្ទះមួយដែលខ្ញុំជួល។ អ្នកដែលមានចិត្តចង់មែនទែន ក៏រួមគ្នាជាមួយខ្ញុំដើម្បីរៀបចំកម្មវិធី។

គោលដៅគឺធ្វើយ៉ាងណាដើម្បីកំចាត់ស្ថានភាពជាអ្នកចាញ់អាមាសមុខនៃជនភៀសខ្លួនឲ្យបាត់ ហើយក្រឡាស់ជាល្អវិញ។ អ្នកទាំងនោះត្រូវតែត្រឡប់ចូលកម្ពុជាវិញដោយងើបមុខ មិនមែនឱនមុខសូមទានពីប្រទេសមួយដែលកំពុងក្រខ្សត់នោះទេ។ គេត្រូវបង្ហាញនិងផ្តល់ចំណេះដែលមានទៅអ្នកដែលក្រជាងនោះ

---

[7] កំណត់អ្នកប្រែ ៖ ជម្រុំជំណាក់ (Camp de transit) ជាជម្រុំស្នាក់បណ្តោះអាសន្នមុននឹងចេញទៅទីណាមួយទៀត។

ទៅទៀត។ ពេលនោះដាងនៅពេលណាទៀតទាំងអស់ ខ្ញុំមិនចង់ឲ្យសិស្សខ្ញុំជ្រើសរើសយកតវិយាបទជាអ្នករងគ្រោះឡើយ។ កាលពីពួកគេនៅជាកូនក្មេង ស្លៀកពាក់រយ៉ីរយ៉ៃ, ខ្លួនក្រខ្វក់, នៅក្នុងជម្រុំនៅឡើយ ខ្ញុំមើលឃើញថាពួកគេជាកូនទេព្តាកំពុងរាំនៅជ្រោះមួយដ៏សែនជ្រៅ។ តាមពិតទៅពួកគេជាកូនទេព្តាមែន។ គំនូរដែលពួកគេតែងយកមកឲ្យខ្ញុំមើល បង្ហាញថាគេជាអ្នកជា, ឈរត្រង់ខ្លួនយ៉ាងសង្ហា, ឥតមានផ្អែកលើអ្វីដែលបំភាន់ភ្នែក ហើយដែល Joseph Conrad ថានោះឡើយ។ ខ្ញុំខិតខំធ្វើយ៉ាងណាឲ្យអ្នកទាំងនោះនៅឈរត្រង់ខ្លួនដូច្នេះតទៅទៀតថ្វីត្បិតតែឧបសគ្គមានគ្រប់បែបយ៉ាង។ជាអកុសលបព្វជិតធំៗខាងលើមិនអនុញ្ញាតិឲ្យលោកឪពុក Pierre ចូលមកស្រុកខ្មែរទេ។ ក្នុងបរិបទនិងទំនោរទូទៅនៅទសវត្ស១៩៩០នោះ គឺមាននរណាម្នាក់នៅទីឆ្ងាយណាមួយមិនដឹង ធ្វើសេចក្តីសម្រេចពីបន្ទប់ការិយាល័យរបស់ខ្លួនថា លោកឪពុកគ្មានចំណែកអ្វីត្រូវចូលរួមទៀតទេនៅក្នុងប្រវត្តិសាស្ត្រដែលត្រូវសរសេរនេះ។ សេចក្តីសម្រេចនេះធ្វើឲ្យខ្ញុំក្តុកក្តួលយ៉ាងខ្លាំង ព្រោះបើមានលោកឪពុកនៅជិត ច្បាស់ជាការងាររយើងមានសន្ទុះយ៉ាងលឿន។ កូនសិស្សខ្ញុំទាំងនោះពុំទាន់ចាស់ចិត្តចាស់គំនិតគ្រប់គ្រាន់អាចនឹងកាន់កម្មវិធីការងារធំៗបាននៅឡើយ។ គេកំពុងរស់នៅក្នុងជីវិតដែលតែងតែពុះកញ្ជ្រោល ព្រោះខ្លះនៅជាក្មេងជំទង់ ខ្លះទៀតកំពុងចាប់ផ្តើមពេញវ័យនៅឡើយ។ សមាគមរបស់ខ្ញុំមានរចនាសម្ព័ន្ធសាមញ្ញមែនទែន ហើយខ្ញុំតែម្នាក់ឯងខិតខំរៀបចំយ៉ាងណាឲ្យបំណងបានសម្រេច។ ខ្ញុំមិនបរិយាយរឿងនេះនៅទីនេះឡើយ។

ខ្ញុំគ្រាន់តែបន្ថែមត្រង់នេះថា ៩ឆ្នាំក្រោយពីខ្ញុំបានប្រគល់ការងារឲ្យសមាគមមួយដែលកាន់កាប់គ្រប់គ្រងដោយកូនសិស្សដើម្បីឲ្យធ្វើការបន្តទៅទៀតមក ខ្ញុំត្រឡប់មកប្រទេសកម្ពុជាម្តងទៀត។ មណ្ឌលនោះរីកចម្រើនទៅមុខ,សកម្មភាពក៏មានច្រើនបែប,កម្រឹតសិល្បៈក៏កាន់តែខ្ពស់។មណ្ឌលនោះប្រៀបបីដូចជាបេះដូងដែលកំពុងធ្វើការយ៉ាងសកម្ម ហើយស្រូបទាក់ទាញថាមពលនិងសេចក្តីសង្ឃឹមពីជននានាពីសង្កាត់នោះព្រមទាំងរាលដាលទៅហួសពីនោះទៀតផង។ សេចក្តីសង្ឃឹមដែលមានពីមុនមក គឺចេញមកជាផ្លែផ្កាមែន។ សិស្សទាំងប៉ុន្មាននោះ ក្លាយទៅជាអ្នកសាបព្រួសបណ្តុះស្រូវក្នុងថ្នាលទៅលើអ្នកឯទៀត ដូចកាលមុនខ្ញុំធ្លាប់សាបព្រួសបណ្តុះពួកគេដូច្នោះដែរ។ ខ្ញុំដឹងគុណលោកឪពុកជាអនេកដ្បិតលោកឪពុកនេះហើយដែលធ្វើឲ្យយើងទាំងអស់គ្នាទៅជាម្ចាស់ការបាន។

នៅខែឧសភា ឆ្នាំ២០១២ ខ្ញុំទៅឥណ្ឌាដើម្បីលាលោកឪពុកជាចុងក្រោយបង្អស់។ គាត់អាយុ៩៨ឆ្នាំ ហើយពេលខ្លះគាត់ដឹងខ្លួនតែពាក់កណ្តាលប៉ុណ្ណោះ ឯសម្បកខ្លួនគាត់ស្ទើរតែលែងមានចលនាអ្វីទាំងអស់។ ពេលខ្លះគាត់ភ្ញាក់ស្វាងឡើងវិញ ហើយឆ្លើយឆ្លងជាមួយអ្នកដែលនៅជុំវិញគាត់។ គាត់សួរម៉ោងគេ ហើយស្តាយពេលវេលាដែលកន្លងទៅ ហើយដែលគាត់មិនបានធ្វើការអ្វី។ ពេលដើរទៅមុខឥតប្រយោជន៍! ខ្ញុំប្រាប់ទៅគាត់ថាការដែលគាត់បានធ្វើកន្លងមកនោះគឺធំធេងឥតគណនា ឥឡូវនេះគាត់អាចសម្រាកម្តង។ គាត់តែងតែឆ្លើយមកវិញថា ៖ "កាលនោះខ្ញុំអាចធ្វើបានលើសពីខ្ញុំបានធ្វើទៅទៀត"[8]។ មួយសន្ទុះក្រោយមកគាត់ថា៖ "ទេ!

[8] កំណត់អ្នកប្រែ ៖ ប្រសិនបើកាលនោះខ្ញុំចង់ឬខ្ញុំខំប្រឹងមែនទែន។

*ខ្ញុំគួរតែធ្វើលើសពីនោះ"។*

*រូបភាពក្រោយបង្អស់ដែលដក់ក្នុងក្បាលខ្ញុំ គឺនៅពេលដែលគាត់ដឹងខ្លួនម្តងនោះ គាត់ប្រឹងងើបពីកៅអីរុញ[9] យកដៃតោងភ្ជាក់ដៃដែលហ៊ុំព័ទ្ធទីធ្លាក្នុងយ៉ាងតតេះតតះដើម្បីឈរ។ មិនខុសអ្វីពីអ្នកចម្បាប់ជើងចាស់ ដែលតោងសាយរៀនរហូតដល់ទីបញ្ចប់, ឈររហូត, ត្រៀមខ្លួនប្រយុទ្ធតទៅទៀត។*

[9] *កំណាត់អ្នកប្រែ ៖ សម្រាប់អ្នកពិការដើរមិនរួច។*

# បទសម្ភាសន៍ស្ថាបនិករបស់ហ្វារ

*ស្រី បណ្ឌូល [ស.ប.] ឃួន ដែត [ឃ.ដ.] ស្វាយ សារ៉េត [ស.ស.] និង តោ វុត្ថា [ត.វ.]*

តើអ្នកចាប់ផ្តើមរៀនសិល្បៈនៅអាយុប៉ុន្មាន ? តើអ្នកចងចាំលើកដំបូងដែលអ្នកបានគូរគំនូរទិដ្ឋភាពបន្ទាប់រៀនរបស់អ្នកគ្រូ Véronique Decrop នៅសាយធូដៃរឬទេ ? ហើយអ្នកបានធ្វើអ្វីខ្លះពេលនោះ ?

*ស.ប.៖ ខ្ញុំបានចាប់ផ្តើមរៀនសិល្បៈកាលពីខ្ញុំមានអាយុ១៣ឆ្នាំ។ ពេលនោះ មុនខ្ញុំបានចូលរៀនថ្នាក់ជាមួយអ្នកគ្រូ*Véronique*។ ខ្ញុំពុំបានយល់ប៉ុន្មានទេ គ្រាន់នឹកថាជាថ្នាក់គំនូរសិល្បៈសម្រាប់កម្សាន្តប៉ុណ្ណោះ។ ជាមួយអ្នកគ្រូ* Véronique *ខ្ញុំចាំបានថា ខ្ញុំចាប់ផ្តើមគូរគំនូរដំបូងដោយប្រើខ្មៅដៃ។ ពេលនោះអ្នកគ្រូបានទុកឲ្យខ្ញុំគូរអ្វីៗដោយសេរី មុនពេលគាត់ប្រាប់ខ្ញុំឲ្យគូរគំនូរនេត្រាទស្សន៍ "ពាស្ទិចទីវ" អំពីទិដ្ឋភាពខាងក្នុងថ្នាក់រៀន។*

*ឃ.ដ.៖ ខ្ញុំចាប់ផ្តើមរៀនសិល្បៈនៅអាយុ១៤ឆ្នាំ។ ខ្ញុំពិតជាចងចាំនូវគំនូរដំបូងដែលខ្ញុំបានគូរនៅជម្រុំសាយធូក្នុងថ្នាក់របស់ម្តាយធម៌របស់ខ្ញុំ គឺអ្នកគ្រូ*Véronique *ហើយវាស្ថិតនៅក្នុងចិត្តខ្ញុំជានិច្ច។ វាជាគំនូរស-ខ្មៅដែលគូរដោយខ្មៅដៃនូវរូបទេសភាពមានមនុស្សបាញ់គ្នាទៅវិញទៅមក។ គ្រប់ពេលដែលខ្ញុំមកថ្នាក់រៀន ខ្ញុំតែងតែគូរគំនូរអំពីមនុស្សបាញ់គ្នារាល់ពេលព្រោះទិដ្ឋភាពទាំងនោះដក់ជាប់ក្នុងចិត្តនិងអារម្មណ៍របស់ខ្ញុំ។ ក្រោយមក ខ្ញុំបានជ្រើសយកទិដ្ឋភាពមនុស្សអង្គុយក្រោមដើមឈើ និងស្លូចត្រីមកគូរម្តងវិញ។*

*ស.ស.៖ ខ្ញុំចាប់ផ្តើមរៀនគូររូបនៅអាយុ១៣ឆ្នាំ។ ខ្ញុំនៅចាំច្បាស់ថា រូបទីមួយដែលខ្ញុំបានគូរឡើងនោះ គឺទេសភាពស្រុកខ្មែរដែលកើតចេញពីការស្រមៃរបស់ខ្ញុំ។*

*ត.វ.៖ ខ្ញុំចូលសាលាគំនូរនៅអាយុ១៣ឆ្នាំ។ នៅថ្ងៃដំបូងដែលខ្ញុំបានទៅថ្នាក់គំនូររបស់អ្នកគ្រូ*Véronique *គឺខ្ញុំបានឈរនៅខាងក្រៅថ្នាក់ ប៉ុន្តែខ្ញុំអាចមើលឃើញទៅដល់ខាងក្នុងដោយសារតែថ្នាក់រៀននោះធ្វើពីឬស្សី។ គាត់បានឃើញខ្ញុំតាមប្រឡោះជញ្ជាំង ហើយគាត់បានសួរខ្ញុំថាតើអ្នកចង់ធ្វើអ្វី? ខ្ញុំឆ្លើយថាខ្ញុំចង់គូរគំនូរ។ សំណួរនេះនៅតែស្ថិតនៅក្នុងអារម្មណ៍របស់ខ្ញុំរហូតដល់សព្វថ្ងៃ។ ក្រោយមក ខ្ញុំដើរចូលទៅក្នុងថ្នាក់រៀន ស្របពេលដែលអ្នកគ្រូកំពុងឲ្យក្រដាសទៅសិស្សដទៃទៀតក្នុងថ្នាក់។ បន្ទាប់ពីខ្ញុំចុះឈ្មោះហើយ អ្នកគ្រូបានហុចក្រដាសបន្ទាត់ និងជ័រលុបមកខ្ញុំ។ ពេលនោះគាត់ប្រាប់ឲ្យខ្ញុំគូរនូវអ្វីដែលខ្ញុំឃើញក្នុងថ្នាក់រៀននោះ។ ដូច្នេះ គំនូរដំបូងរបស់ខ្ញុំ គឺទិដ្ឋភាពនៅក្នុងថ្នាក់រៀន (ខ្ញុំមិនដឹងរបៀបគូរនោះទេ នៅពេលនោះ ខ្ញុំគ្រាន់តែដឹងថាខ្ញុំចូលចិត្តគូរគំនូរ)។*

តើអ្វីជាចំណុចសំខាន់បំផុតដែលអ្នកបានរៀនទាក់ទងនឹងសិល្បៈនិងការបង្កើតសិល្បៈពីអ្នកគ្រូ Véronique?

*ស. ប.៖ ចំណុចសំខាន់ដែលខ្ញុំបានរៀនពីអ្នកគ្រូ* Véronique *គឺជីវិតរបៀបគូរគំនូរពាស្តិចទីវ។ តាមពិតទៅអ្នកគ្រូពុំបានបង្រៀនរបៀបគូរនេត្រាទស្សន៍នោះទេប៉ុន្តែអ្នកគ្រូជំរុញខ្ញុំឲ្យស្វែងយល់អ្វីៗទាំងនោះដោយខ្លួនឯង។ អ្វីដែលសំខាន់បំផុតនោះ គឺការផ្លាស់ប្តូរចិត្តគំនិត និងសេចក្តីចេះពិចារណាដឹងខុស។*

*ឃ. ជ.៖ ដំបូងខ្ញុំមិនដឹងថាខ្ញុំបានរៀនអ្វីដែលសំខាន់បំផុតអំពីសិល្បៈនិងការបង្កើតសិល្បៈពីអ្នកគ្រូ* Véronique *ទេ ខ្ញុំគ្រាន់តែដឹងថា នៅពេលខ្ញុំមករៀន ខ្ញុំមានអារម្មណ៍ថាមានសេរីភាពក្នុងការគូរ និងការបញ្ចេញអារម្មណ៍របស់ខ្ញុំ។ ខ្ញុំបានមករស់នៅក្នុងមជ្ឈមណ្ឌលកុមារយោធិន និងត្រូវបានគេបង្ខំឲ្យខ្ញុំត្រូវរៀនរាល់បច្ចេកទេសទ័ពដែលធ្វើឲ្យខ្ញុំមានដែលធ្វើឲ្យខ្ញុំរងការឈឺចាប់ ដែលជាហេតុធ្វើឲ្យខ្ញុំត្រូវការបញ្ចេញអារម្មណ៍ធុញថប់ និងជម្នះការលំបាកទាំងនោះ។ នៅពេលចាប់ផ្តើមដំបូង ខ្ញុំមិនមានអារម្មណ៍ថា ខ្ញុំរៀនគូរនោះសម្រាប់អាជីពរបស់ខ្ញុំ ឬក្លាយខ្លួនជាវិចិត្រករឬសិល្បករអាជីពនោះទេ ប៉ុន្តែខ្ញុំគ្រាន់តែរៀនសម្រាប់កម្សាន្តនិងបញ្ចេញអារម្មណ៍របស់ខ្ញុំ គឺខ្ញុំគូរអ្វីដែលខ្ញុំចង់គូរប៉ុណ្ណោះ។ នៅពេលដែលខ្ញុំមានវ័យចាស់កាលបន្តិច ខ្ញុំដឹងថា ខ្ញុំបានយល់និងរៀនអំពីថាតើសិល្បៈមានសេរីភាពបរិបូណ៌យ៉ាងណា និងមានភាពសំខាន់យ៉ាងដូចម្តេចសម្រាប់ការបញ្ចេញអារម្មណ៍និងគំនិត ព្រមទាំងសម្រាប់ការអភិវឌ្ឍន៍។*

*ស. ស.៖ អ្នកគ្រូធ្វើឲ្យខ្ញុំបានយល់ពីសេរីភាពនៅក្នុងការបញ្ចេញគំនិតតាមរយៈគំនូរនិងរំដោះរាល់អនុស្សាវរីយ៍អាក្រក់កាលពីកុមារភាពបានជួបប្រទះតាមរយៈការគូររូបនិងផាត់ពណ៌។ អ្នកគ្រូបានបង្រៀនខ្ញុំចេះផាត់ពណ៌ជីវិតរបស់ខ្ញុំ។*

*ត. វ.៖ អ្វីដែលសំខាន់បំផុតនោះដែលខ្ញុំបានរៀន គឺរបៀបបញ្ចេញអារម្មណ៍របស់ខ្លួននៅក្នុងសិល្បៈ, របៀបផ្តល់ឲ្យនិងចែករំលែកជាមួយអ្នកដទៃ និងរបៀបរស់នៅជាក្រុមរួមគ្នាក្នុងសង្គមមួយ។*

តើអ្នកគិតថាហេតុអ្វីបានជាអ្នកគ្រូ Véronique សម្រេចចិត្តបង្កើតឡើងវិញនូវសាលាសិល្បៈហ្វារនៅបាត់ដំបង?

*ស. ប.៖ ខ្ញុំគិតថា អ្នកគ្រូត្រូវតែបន្ត ព្រោះអ្នកគ្រូស្រឡាញ់និងអាណិតពួកយើង និងចង់ឲ្យពួកយើងក្លាយជាអ្នកសិល្បៈនាពេលអនាគត។ ម្យ៉ាងទៀតពីព្រោះវាជាពេលវេលាដ៏វិសេសនិងសំខាន់បំផុតសម្រាប់ប្រទេសកម្ពុជា ដើម្បីប្រើប្រាស់សិល្បៈក្នុងការតស៊ូមតិ ការព្យាលបាលផ្លូវចិត្តនិងគំនិត និងការកត់ត្រាប្រវត្តិសិល្បៈផង។ មូលហេតុទាំងនេះហើយដែលអ្នកគ្រូជម្រុញពួកយើងអស់ពីកាយពីចិត្ត និងថែមទាំងគ្រប់គ្រងពួកយើងនៅពេលយើងចាប់ផ្តើមដំណើរការហ្វារនាគ្រាដំបូងនោះ។*

*ឃ. ជ.៖ នៅពេលធ្វើមាតុភូមិនិវត្តន៍ពីជម្រុំមកវិញ ខ្ញុំតែងតែគិតថា ខ្ញុំត្រូវបន្តនូវសកម្មភាពពីជម្រុំ ប៉ុន្តែខ្ញុំនិង*

*មិត្តភក្តិជ្រទៃទៀតគ្មានគំនិតនិងមធ្យោបាយត្រូវបន្តវាយ៉ាងដូចម្តេចនោះទេ ព្រោះយើងគ្មានថវិកាសោះ ដើម្បីបង្កើតសាលាសិល្បៈនិងជំនាញនេះ។ សំណាងល្អដែរ ពេលនោះ អ្នកគ្រូ* Véronique *ក៏បានមកបាត់ដំបងដែរ ហើយអ្នកគ្រូបានជួយរៀបចំបង្កើតឡើងវិញនូវសកម្មភាពទាំងឡាយដូចនៅកាលពីអតីតនៅជម្រុំសាយធូ។ ដំបូងអ្នកគ្រូគ្រាន់តែចង់បង្កើតនូវសហគ្រាសតូចមួយព្រោះគាត់ចង់ឲ្យពួកយើងមានការងារធ្វើនិងអាចបង្ករឲ្យពួកយើងឲ្យបន្តបេសកកម្មក្នុងវិស័យសិល្បៈតទៅទៀត។ ទាំងនេះ អ្នកគ្រូពុំធ្លាប់គិតថានឹងបង្កើតអង្គការធំដូចអង្គការហ្វារពន្ធឺសិល្បៈសព្វថ្ងៃនេះឡើយ។*

*ស. ស.៖ ពីព្រោះ អ្នកគ្រូ* Véronique *ចង់បន្តជួយនិងជម្រុញពួកយើងសម្រាប់វិស័យសិល្បៈនេះ និងថែមទាំងចង់ឲ្យពួកយើងនៅតែបន្តចែករំលែកបទពិសោធន៍នេះទៅមនុស្សដែលនៅក្បែរពួកយើងផង។ លើសពីនេះគឺអ្នកគ្រូមានបំណងលើកស្ទួយ និងស្តារឡើងវិញនូវសិល្បៈវប្បធម៌ខ្មែរជាពិសេស។*

*ត. វ.៖ សម្រាប់ចំណុចនេះ ខ្ញុំចង់និយាយភ្ជាប់ទៅនឹងរឿងរាវដែលជាប់ទាក់ទងគ្នាក្នុងជម្រុំជនភៀសខ្លួនសាយធូក្នុងជាយដែនខ្មែរ-ថៃ។ មុនពេលធ្វើមាតុភូមិនិវត្តន៍ចូលស្រុកខ្មែរវិញ អ្នកគ្រូ* Véronique *បានសុំអាស័យដ្ឋានរបស់ពួកយើងនៅស្រុកខ្មែរ ពីព្រោះគាត់ចង់បន្តគម្រោងនៃសាលាសិល្បៈនៅក្នុងស្រុកខ្មែរ បើទោះជាពេលនោះ យើងពុំដឹងអ្វីបន្តិចសោះអំពីស្ថានភាពជាក់ស្តែងនៅស្រុកខ្មែរក៏ដោយ។ អ្នកគ្រូព្រួយបារម្ភអំពីអនាគតរបស់ពួកយើង ពេលត្រឡប់មករស់នៅក្នុងស្រុកយើងវិញ។ ហេតុទាំងនេះហើយបានជាគាត់បង្កើតសាលាដើម្បីផ្តល់ការងារឲ្យពួកខ្ញុំធ្វើ។ ហេតុអ្វីត្រូវរើសខេត្តបាត់ដំបង? ពីព្រោះប្រវត្តិរបស់ពួកយើងភាគច្រើនគឺក្នុងតំបន់នេះហើយជនភៀសខ្លួនជាច្រើនបានត្រឡប់មករស់នៅក្នុងខេត្តនេះ។ លើសពីនេះទីក្រុងតូចល្មមនិងស្ងប់ស្ងាប់នេះផ្តល់ភាពងាយស្រួលសម្រាប់ការសិក្សាស្រាវជ្រាវនិងរៀបចំបង្កើតស្នាដៃសិល្បៈ។ អ្វីដែលខ្ញុំចង់ចាំបាន គឺអ្នកគ្រូ* Véronique *ចង់បង្កើតកន្លែងនេះជាផ្នែកមួយនៃប្រវត្តិសិល្បៈកម្ពុជា។*

តើនៅពេលណា និងហេតុអ្វីបានជាអ្នកចូលរួមជាមួយអ្នកគ្រូ Véronique បង្កើតឡើងវិញនូវសាលាសិល្បៈហ្វារនៅបាត់ដំបងនេះ ?

*ស. ប.៖ ខ្ញុំគិតថាប្រហែលពីរខែក្រោយ អ្នកគ្រូ* Véronique *បានមកដល់ស្រុកខ្មែរក្នុងឆ្នាំ១៩៩២។*

*ឃ. ជ.៖ ខ្ញុំបានជួបអ្នកគ្រូ* Véronique *ក្នុងឆ្នាំ១៩៩៣ ដើម្បីបង្កើតឡើងវិញនូវសាលាសិល្បៈនៅខេត្តបាត់ដំបង។ ខ្ញុំចូលរួមជាមួយអ្នកគ្រូ ព្រោះខ្ញុំចង់បន្តនូវអ្វីដែលខ្ញុំបានរៀននៅជម្រុំ និងចែករំលែកវាជាមួយនឹងកុមារ ជាពិសេសសម្រាប់អ្នកដែលមានទុក្ខព្រួយពីជីវភាពប្រចាំថ្ងៃរបស់ខ្លួន។ នេះមិនគ្រាន់តែប៉ុណ្ណឹងទេ ដែលជាហេតុនាំមានហ្វារ ប៉ុន្តែជាអ្វីដែលខ្ញុំចូលចិត្តនិងចង់ធ្វើនៅពេលទំនេរផង។*

ស.ស.៖ ខ្ញុំបានជួបអ្នកគ្រូ Véronique នៅឆ្នាំ១៩៩៤ ដើម្បីចូលរួមរៀបចំបង្កើតហ្វារ ពីព្រោះទាំងនោះជាអ្វីដែលខ្ញុំស្រឡាញ់ហើយចង់ធ្វើវា។

ត.វ.៖  ខ្ញុំបានសម្រេចចិត្តចូលរួមក្នុងការបង្កើតសាលាសិល្បៈហ្វារនៅបាត់ដំបងនៅឆ្នាំ១៩៩៣ជាមួយអ្នកគ្រូ Véronique។

តើឧបសគ្គអ្វីខ្លះ ដែលអ្នកបានពើបប្រទះក្នុងពេលបង្កើតសាលាសិល្បៈហ្វារនេះ ?

ស.ប.៖  ខ្ញុំចាំបានថា វាពិបាកខ្លាំងណាស់ពេលដែលយើងចាប់ផ្តើមសាលា ខ្ញុំត្រូវរៀនគូរបន្ថែមដោយខ្លួនឯងដើម្បីក្លាយខ្លួនជាគ្រូគំនូរផង និងខ្ញុំធ្វើការដូចជាកម្មករទូទៅផង ( រែកដី, ជីកស្រះ, បូមទឹក, ធ្វើផ្លូវ)។ ខ្ញុំបានជួបនូវបញ្ហាជាច្រើនអំពីការទំនាក់ទំនង ពីព្រោះខ្ញុំកាលនោះនៅក្មេងខ្ចី ទទួលការអប់រំតិចតួច និងមានប្រវត្តិជាអ្នកភៀសខ្លួនផង។បញ្ហាដែលសំខាន់បំផុតនោះគឺពួកយើងបានពុំដឹងអំពីរបៀបបង្រៀនទេ ពីព្រោះអ្នកគ្រូVéroniqueមិនដែលធ្លាប់បង្រៀនផ្នែកគុរុកោសល្យដល់ពួកយើងឡើយ។ ដូច្នេះខ្ញុំខំព្យាយាមនិទានរឿងច្រៀងចម្រៀង  និងចំណាយប្រាក់ខែ៣០ដុល្លាររបស់ខ្ញុំខ្លះសម្រាប់ទិញស្ករគ្រាប់ចែកសិស្សរបស់ខ្ញុំ។  ពេលនោះខ្ញុំគិតថាជាពេលល្អបំផុតដែលខ្ញុំអាចរំលែកដល់សិស្សរបស់ខ្ញុំឲ្យបានច្រើនបំផុតអំពីជីវិតនិងសេចក្តីស្រឡាញ់ដូចដែលអ្នកគ្រូ Véronique បានធ្លាប់បង្រៀនខ្ញុំ។

ឃ.ឌ.៖ មុនពេលចាប់ផ្តើមការសាងសង់សាលា យើងត្រូវការចាក់បំពេញដីបន្ថែម  ពេលនោះពួកត្រូវធ្វើជាកម្មករដោយខ្លួនឯងដើម្បីរែកដីចាក់បំពេញកន្លែងរៀបចំនោះ  ជាមួយប្រជាជនដទៃទៀតក្នុងសហគមន៍ក្បែរនោះ ព្រោះយើងគ្មានថវិកាគ្រប់គ្រាន់ក្នុងការជួលកម្មករនោះទេ។ យើងចាប់ផ្តើមការងារដោយគ្មានការគាំទ្រ  គ្មានបៀវត្ស  និងគ្មានជំនាញក្នុងការគ្រប់គ្រង។  យើងគ្រាន់តែដឹងអំពីរបៀបបង្រៀនខ្លះប៉ុណ្ណោះ។ ដោយសារសហគមន៍ជុំវិញជាសហគមន៍ក្រីក្រ ពួកគេមិនមានចំណាប់អារម្មណ៍ក្នុងការបញ្ជូនកូនៗរបស់ពួកគេឲ្យចូលរួមក្នុងសកម្មភាពជាមួយយើងទេ ពួកគេគិតតែពីជីវភាពប្រចាំថ្ងៃរបស់ពួកគេប៉ុណ្ណោះដោយគេគិតថាការចូលរួមសកម្មភាពជាមួយពួកយើងធ្វើឲ្យខាតបង់ពេលវេលា។  សកម្មភាពចាប់ផ្តើមដំណើរការបន្តិចម្តងៗពីមួយថ្ងៃទៅមួយថ្ងៃ រហូតពួកគេ [សហគមន៍ជុំវិញ] បានយល់អំពីសារសំខាន់របស់សិល្បៈ។

យើងបានជួបនូវការលំបាកមួយទៀតក្នុងឆ្នាំ១៩៩៦ នៅពេលដែលអ្នកគ្រូ Véronique ចេញទៅប្រទេសបារាំងដោយបញ្ហាសុខភាព ហើយបានទុកពួកយើងឲ្យនៅតែឯង គ្មានការគាំទ្រ គ្មានបៀវត្ស គ្មានការគ្រប់គ្រង  ហើយស្ថាបនិកមួយចំនួនក៏បានចាកចេញទៅ  ដោយមូលហេតុផ្សេងៗរបស់ពួកគេ  ដូច្នេះខ្ញុំត្រូវដឹកនាំសាលាជាមួយនឹងមិត្តភក្តិម្នាក់របស់ខ្ញុំ គឺលោក ស្វាយ សារ៉េត ដែលពីដំបូងពួកយើងក៏បម្រុងនឹងចាកចេញពីសាលានេះដែរ  ពេលឃើញស្ថាបនិកផ្សេងទៀតបានចាកចេញអស់នោះ។  ខ្ញុំបានសម្រេចចិត្តថានៅបន្ត

*ព្រោះខ្ញុំមានអារម្មណ៍ថា សាលាគឺពួកយើងជាអ្នកបង្កើតវាដោយខ្លួនឯង ដោយមានការខិតខំប្រឹងប្រែងខ្លាំង និងព្រមជាមួយញើសឈាមរបស់អ្នកគ្រូ Véronique ដែលជាម្ដាយធម៌ដ៏ល្អបំផុតរបស់ពួកយើង។ យើងបានជួបប្រទះនូវបញ្ហាមួយទៀតក្នុងឆ្នាំ១៩៩៩ ដោយយើងកង្វះខាតថវិកាសម្រាប់ដំណើរការសកម្មភាព ដែលជម្រុញឲ្យពួកយើងខ្វះថវិកាពីដៃគូរបស់យើង (អង្គការកុមារកៀសខ្លួនពិភពលោក)។ ក្នុងឆ្នាំ២០០២ពួកយើងបានជួបនូវបញ្ហាថវិកាម្ដងទៀត ដោយក្នុងពេលនេះ គឺដៃគូរបស់យើងមានភាពមិនស្មោះត្រង់ ហើយប្រើប្រាស់ថវិការបស់យើងសម្រាប់ធ្វើសកម្មភាពរបស់ពួកគេ ដូច្នេះខ្ញុំបានសម្រេចចិត្តក្នុងការបញ្ចប់ទំនាក់ទំនងជាដៃគូជាមួយពួកគេ។*

*សុ.សុ.៖ ខ្ញុំគ្មានបទពិសោធន៍គ្រប់គ្រាន់ មិនយល់ពីទិសដៅពិតប្រាកដនៃគម្រោង និងគ្មានការជឿជាក់អ្វីទេពេលនោះ។*

*ឆ.វ.៖ ខ្ញុំគ្មានបទពិសោធន៍ការងារ និងមិនធ្លាប់ឆ្លងកាត់សាលាគរុកោសល្យបង្រៀនទាល់តែសោះ។ ដូច្នេះអ្វីដែលខ្ញុំបង្រៀនសិស្សគឺធ្វើតាមរបៀបដូចដែលអ្នកគ្រូធ្លាប់បង្រៀនខ្ញុំនៅជម្រុំសាយធូ។ លើសពីនេះទៅទៀត បញ្ហាជីវភាពរស់នៅពេលនោះគឺបានចោទយ៉ាងខ្លាំងសម្រាប់ខ្ញុំ។ ខ្ញុំបានទទួលប្រៀវត្សរ៍តិចបំផុត (ត្រឹមតែ៥ដុល្លារអាមេរិកក្នុងមួយខែ)។ លើសពីនោះ យើងធ្វើការជាមួយក្មេងច្រើនប្រភេទលាយឡំគ្នា ក្មេងខ្លះមកពីគ្រួសារដែលទីទល់ក្រលំបាកតោកយ៉ាក និងក្មេងខ្លះទៀតមកពីគ្រួសារដែលប្រើអំពើហឹង្សា។*

តើវាមានន័យយ៉ាងដូចម្តេចចំពោះអ្នក កាលដែលអ្នកជាស្ថាបនិកម្នាក់នៃអង្គការហ្វារពន្លឺសិល្បៈនេះ? ហើយតើអ្នកត្រូវនៅទទួលខុសត្រូវលើចំណុចណាខ្លះដែរឬទេ នាពេលបច្ចុប្បន្ន? បើបានផ្តល់, សូមមេត្តារៀបរាប់ចំណុចខ្លះអំពីភាពទទួលខុសត្រូវទាំងនោះ?

*សុ.ប.៖ ដំបូងឡើយ ខ្ញុំពុំបានយល់អ្វីទៅជា "ស្ថាបនិក" និងមានន័យយ៉ាងណានោះទេ។ ប៉ុន្តែក្រោយមកទើបខ្ញុំយល់ពីអត្ថន័យរបស់វា ពោលគឺមានន័យថាជាអ្វីម៉្យាងទាក់នឹងកិត្តិយស និងភាពទទួលខុសត្រូវ។ បច្ចុប្បន្នខ្ញុំជាសមាជិកក្រុមប្រឹក្សារបស់ហ្វារ ខ្ញុំមានតួនាទីនៅក្នុងក្រុមការងារថ្នាក់គ្រប់គ្រង និងគណៈកម្មការសាងសង់ និងជាពិសេសខ្ញុំទទួលខុសត្រូវដោយផ្ទាល់ខ្លួនឯងទៅលើកិច្ចការទូទៅមួយចំនួនដូចជាការដាំដើមឈើ, ការសម្អាតទីធ្លា និងការជួយមើលសុវត្ថិភាពនិងសន្តិសុខសាលា។*

*ឃ.ជ.៖ សម្រាប់ខ្ញុំ "ស្ថាបនិក" សំដៅលើអ្នកដែលចូលរួម និងជួយបង្កើតសាលាដោយមិនគិតពីពេលវេលាវែងឬខ្លីឡើយ។ ក្នុងនាមជាស្ថាបនិកម្នាក់ដំបូងវាហាក់ពុំមានសារសំខាន់សម្រាប់ខ្ញុំទេប៉ុន្តែក្នុងឆ្នាំ១៩៩៦ខ្ញុំហាក់មានអារម្មណ៍ថាវាមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំ នៅពេលដែលខ្ញុំព្យាយាមតស៊ូដឹកនាំសាលានេះជាមួយមិត្តភក្តិដ៏កម្សត់របស់ខ្ញុំ ដែលពេលនោះយើងមានទំនួលខុសត្រូវច្រើនក្នុងការដឹកនាំសាលាមួយនិង*

*ធ្វើឲ្យសាលានោះសម្រេចបាននូវគោលដៅរបស់ខ្លួន។ វាហាក់ដូចជាកាន់តែសំខាន់ឡើងៗសម្រាប់ខ្ញុំក្នុងឆ្នាំ ១៩៩៩ នៅពេលដែលយើងត្រូវតស៊ូម្តងទៀតអំពីរឿងថវិកា ដើម្បីដំណើរការសាលា។ ជាថ្មីទៀតវាកាន់តែនាំមកនូវទំនួលខុសត្រូវច្រើនឡើងៗថែមទៀតសម្រាប់ខ្ញុំក្នុងឆ្នាំ២០០២ ដែលខ្ញុំត្រូវប្រឈមមុខជាមួយដៃគូរបស់យើងក្នុងការតស៊ូមតិដើម្បីទទួលបានថវិការបស់យើងត្រឡប់មកហ្វារពន្លឺសិល្បៈវិញនិងបញ្ចប់ភាពជាដៃគូ។ ភាពមានទំនួលខុសត្រូវច្បាស់និងពិតប្រាកដក្នុងនាមជាស្ថាបនិកម្នាក់ត្រូវ ៖*

- *គិតពីផលប្រយោជន៍ហ្វារពន្លឺសិល្បៈជារួម ជាជាងគិតពីផលប្រយោជន៍បុគ្គល។*
- *ជួយតម្រង់ទិសក្នុងការដឹកនាំហ្វារពន្លឺសិល្បៈទៅកាន់ទស្សនវិស័យ និងបេសកម្មរបស់ខ្លួនប្រកបដោយបរិយាកាសសុវត្ថិភាពនិងជោគជ័យ។*
- *ទទួលខុសត្រូវលើរាល់ការងារដែលកំពុងធ្វើ។*
- *រក្សាព្រលឹងរបស់ហ្វារពន្លឺសិល្បៈឲ្យគង់វង្ស។*
- *គិតជាចម្បងអំពីគុណប្រយោជន៍របស់កុមារ។*

ស. ស.៖ *គឺជាសំណាងមួយដែលបានក្លាយជាស្ថាបនិករបស់អង្គការហ្វារពន្លឺសិល្បៈ។ ទាំងអស់នេះបានធ្វើឲ្យខ្ញុំមានអារម្មណ៍ចេះទទួលខុសត្រូវ និងមានទស្សនៈពិចារណានិងរិះគន់ចំពោះការវិវត្តន៍នៃសិល្បៈ-វប្បធម៌សហសម័យ។ ពេលនោះហើយ ដែលធ្វើឲ្យខ្ញុំហាក់គិតថា ខ្ញុំគឺជាអ្នកថែរក្សាវប្បធម៌ [ឆ្មាំវប្បធម៌] និងជាអ្នកឃ្លាំមើលពីការវិវឌ្ឍន៍សិល្បៈខ្មែរក្នុងសម័យបច្ចុប្បន្ននេះ។*

ត. វ.៖ *ក្នុងនាមជាស្ថាបនិករបស់សមាគមហ្វារពន្លឺសិល្បៈពិតជាមានអត្ថន័យណាស់សម្រាប់ខ្ញុំ ដោយសារតែហ្វារពន្លឺសិល្បៈ គឺជាផ្នែកមួយនៃរាងកាយរបស់ខ្ញុំ។ ទន្ទឹមគ្នានេះ វាជាអ្វីមួយដែលរួមគ្នាតែមួយ ដែលរាល់ស្ថាបនិកទាំងអស់បានបូជាការងាររួមគ្នាក្នុងន័យឈានឲ្យដល់ការលើកតម្លៃសង្គមជាតិ សិល្បៈ-វប្បធម៌ និងការអប់រំសម្រាប់ក្មេងៗជំនាន់ក្រោយទៀត។ យើងមានបំណងជាពិសេសស្ថាបនាប្រទេសជាតិឡើងវិញដោយយកសិល្បៈជាមធ្យោបាយមួយក្នុងមធ្យោបាយជាច្រើនទៀត។ ខ្ញុំមានមោទនភាពក្នុងនាមជាស្ថាបនិកសម្រាប់ហ្វារ។ សម្រាប់ឥឡូវខ្ញុំពុំទាន់មានការទទួលខុសត្រូវអ្វីធំដុំឡើយ។ តែទោះបីជាយ៉ាងណាក៏ដោយក្នុងទស្សនៈរបស់ខ្ញុំ ស្ថាបនិកត្រូវតែមានតួនាទីក្នុងការឃ្លាំមើលនិងជម្រុញគាំទ្រនាយកប្រតិបត្តិរបស់ហ្វារ និងព្រមទាំងអភិវឌ្ឍនិងថែរក្សាទិសដៅគោលជំហរ និងគោលបំណងរបស់ហ្វារពន្លឺសិល្បៈឲ្យឈានដល់ការសម្រេចបាននូវលទ្ធផលជាផ្លែផ្កានាពេលខាងមុខ។*

តើអ្នកប្រកបមុខរបរអ្វីខ្លះក្នុងពេលបច្ចុប្បន្ន?

ស. ប.៖ *ខ្ញុំបង្រៀនសិល្បៈនៅហ្វារ និងលក់គំនូរសិល្បៈរបស់ខ្ញុំ។*

*ឃ. ជ.៖ កាលពីមុន ខ្ញុំបានចំណាយពេលទាំងអស់សម្រាប់ហ្វារពន្លឺសិល្បៈ តែឥឡូវខ្ញុំមានគ្រួសារ ខ្ញុំត្រូវចំណាយពេលមួយចំនួន (៣០%) សម្រាប់គ្រួសាររបស់ខ្ញុំ។ ខ្ញុំធ្វើការឲ្យហ្វារពន្លឺសិល្បៈ ហើយមានតួនាទីជានាយកផ្នែកសិល្បៈ និងទស្សនីយភាព។ អ្វីដែលសំខាន់ជាងគេនោះ គឺថាខ្ញុំត្រូវបណ្តុះបណ្តាលក្មេងៗជំនាន់ក្រោយ ដើម្បីឲ្យពួកគេដឹកនាំហ្វារពន្លឺសិល្បៈបន្ត បន្ទាប់ពីខ្ញុំចាកចេញទៅ។ ខ្ញុំដឹងថា ខ្ញុំនឹងពុំអាចនៅហ្វារពន្លឺសិល្បៈ ឬធ្វើការក្នុងហ្វារពន្លឺសិល្បៈមួយជីវិតទេ ខ្ញុំត្រូវការស្វែងរកអ្វីផ្សេងទៀតដើម្បីផ្គត់ផ្គង់គ្រួសាររបស់ខ្ញុំដូចឃើញស្រាប់ ឥឡូវនេះខ្ញុំបានចាប់ផ្តើមអាជីវកម្មតូចមួយរបស់ខ្ញុំសម្រាប់ផ្គត់ផ្គង់បន្ថែមលើជីវភាពរបស់គ្រួសារខ្ញុំ។*

*ស. ស.៖ ខ្ញុំជាសិល្បៈករមួយរូប។*

*ត. វ.៖ ខ្ញុំធ្វើជាគ្រូបង្រៀនគំនូរនៅក្នុងហ្វារពន្លឺសិល្បៈនិងខ្ញុំជាវិចិត្រករឯករាជ្យម្នាក់។*

តើអ្វីជាលក្ខណៈពិសេសដែលសិស្សទទួលបានពីការអប់រំនៅហ្វារ? ហើយវាមានភាពខុសប្លែកគ្នាដូចម្តេចដែរចំពោះសិស្សដែលរៀនវិស័យសិល្បៈនៅកន្លែងឬសាលាសិល្បៈផ្សេងទៀតក្នុងប្រទេសកម្ពុជា?

*ស. ប.៖ ចំពោះខ្ញុំភាពពិសេសជាងគេនៃការអប់រំសិល្បៈនៅហ្វារ គឺសិស្ស ទទួលបាននូវជំនាញផ្នែកសិល្បៈសហសម័យច្រើនប្រភេទដូចជា ផ្នែកគំនូរ, ផ្នែកគំនូរជីវចល, ក្រាហ្វិកឌីសាញ, សៀក និងល្ខោន។ ខុសពីកន្លែងដទៃទៀត ត្រង់ពួកគេអាចរៀនបានតែគូរគំនូរប្រេង ដែលគូរអំពីប្រាសាទអង្គរវត្ត, បាយ័ន្ត, របាំអប្សរា និងទេសភាពស្រុកស្រែតែប៉ុណ្ណោះ។*

*ឃ. ជ.៖ វិធីសាស្រ្តនិងយុទ្ធសាស្រ្តការអប់រំនៅក្នុងហ្វារពន្លឺសិល្បៈមានលក្ខណៈពិសេសប្លែកពីគេដែលសិស្សមិនអាចទទួលបានពីកន្លែងផ្សេងទៀតក្នុងកម្ពុជាឡើយ ដោយសារសិស្សទាំងនោះយល់ស៊ីជម្រៅអំពីតម្លៃនៃសិល្បៈ។ ពួកគេបានទទួលឱកាសសម្រាប់ការច្នៃប្រឌិត (ពិព័រណ៌ស្នាដៃរបស់ពួកគេ សូម្បីនៅពេលពួកគេនៅនៅជាសិស្សក៏ដោយ) ចំណេះដឹង និងជំនាញត្រូវបានទទួលស្គាល់ជាលក្ខណៈជាតិផង និងអន្តរជាតិផង។ ម្យ៉ាងទៀតតាមរយៈការអប់រំនេះ ហ្វារពន្លឺសិល្បៈអភិវឌ្ឍ និងលើកកម្ពស់កុមារ និងយុវវ័យដែលសង្គមមិនរាប់រកឲ្យក្លាយជាធនធានដ៏សំខាន់របស់សង្គម និងទទួលស្គាល់ដោយសង្គម។ បន្ថែមពីលើនេះ ហ្វារពន្លឺសិល្បៈបង្កើតសាលាជំនាញសិល្បៈសូន្យរូបមួយ ដែលជាសាលាដំបូងបង្អស់នៅក្នុងប្រទេសកម្ពុជា។ ហ្វារពន្លឺសិល្បៈបានចាប់ផ្តើមនូវការអប់រំផ្នែកសិល្បៈសហសម័យ [សិល្បៈបច្ចុប្បន្ន] នៅក្នុងប្រទេសកម្ពុជាមុនគេបង្អស់។*

*ស. ស.៖ សិស្សនៅសាលាហ្វារបានយល់ដឹងអំពីការពង្រីកជំនាញផ្នែកសិល្បៈ ដែលនឹងអាចឲ្យពួកគេក្លាយទៅជាអ្នកជំនាញអាជីព និងខ្លះទៀតអាចមានឱកាសក្លាយទៅជាសិល្បៈករដែលទទួលស្គាល់ជាអន្តរជាតិ។*

*ត.វ.៖ ប្រព័ន្ធអប់រំផ្នែកសិល្បៈដ៏ពិសេសបំផុតនៅហ្វារ គឺម្នាក់ៗទទួលបានការសិក្សាជំនាញសិល្បៈដោយឥត បង់ថ្លៃ ដូចជាជំនាញគំនូរ, គំនូរជីវចល, ក្រាហ្វិកឌីសាញ, សៀក, ល្ខោន និងការសិក្សាអប់រំទូទៅរបស់រដ្ឋ។*

តាមការគិតរបស់អ្នក អ្វីទៅជាចំណុចខ្លាំងរបស់សិស្សដែលមករៀនសាលាសិល្បៈសូនរូបរបស់ហ្វារពន្លឺសិល្បៈ និង អ្វីទៅជាចំណុចខ្សោយរបស់ពួកគេ?

*ស.ប.៖ ចំណុចខ្លាំងនិងពិសេសរបស់សិស្សនៅហ្វារ គឺពួកគេមានភាពម្ចាស់ការនិងជំហរខ្លួនឯងរឹងប៉ឹង មានចិត្តទូលំទូលាយនិងមានភាពច្នៃប្រឌិតខ្ពស់ផ្អែកលើអារម្មណ៍និងគំនិតខ្លួនឯងៗចំណែកចំណុចខ្សោយវិញ គឺពួកគេទទួលបានការអប់រំតិចតួចពេក។*

*ឃ.ដ.៖ ចំណុចខ្លាំង ៖*

- *សិស្សដែលសិក្សានៅសាលាសិល្បៈសូនរូបរបស់ហ្វារពន្លឺសិល្បៈ គឺគឺសុទ្ធតែចូលរៀនដោយសារ សម្រេចចិត្តខ្លួនឯង ពុំមានសម្ពាធពីអាណាព្យាបាលរបស់ពួកគេឡើយ។ពួកគេមានគំនិតច្នៃ ប្រឌិតច្រើន ដោយពួកគេបានរៀនច្រើនពីក្នុងថ្នាក់ ជាពិសេសកម្មវិធីសិក្សាថ្មីផ្តល់ដល់ពួកគេនូវ ឱកាសជាច្រើនក្នុងការច្នៃប្រឌិត។*
- *ពួកគេមកពីប្រវត្តិគ្រួសារមានការលំបាក និងសង្គមមិនរាប់រក ឥឡូវពួកគេក្លាយខ្លួនជាជនជាន ដ៏សំខាន់នៅក្នុងសង្គម តាមរយៈបម្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេ ព្រមទាំងការអភិវឌ្ឍន៍ ជំនាញអាជីពរបស់ពួកគេ។*
- *ទទួលស្គាល់ជាលក្ខណៈជាតិផង និងអន្តរជាតិផង ដែលងាយស្រួលរកថវិកាតាមរយៈស្នាដៃ របស់ពួកគេ។*
- *ពួកគេតស៊ូនិងព្យាយាមអស់ពីកម្លាំងកាយចិត្តលើជំនាញអាជីពសម្រាប់អនាគតរបស់ពួកគេ។*

*ចំណុចខ្សោយ ៖*

- *ចំណេះដឹងទូទៅជារនាំងបញ្ហាដ៏ធំរបស់ពួកគេ។ អ្វីដែលពួកគេអាចធ្វើបាន គឺតាមរយៈការស្រមើ ស្រម៉ៃ និងស្រាវជ្រាវតាមអ៊ិនធើណែត។*
- *ចំណេះដឹងដែលគេមាននៅពុំទាន់គ្រាប់គ្រាន់នៅឡើយ ដោយពួកគេមិនមានពេលវេលាច្រើន ក្នុងការសិក្សាពីព្រោះសាលានៅឆ្ងាយពីផ្ទះរបស់ពួកគេ។*
- *សិស្សត្រូវបានបង្ខំឲ្យចាកចេញ ឬឈប់ពីសាលាមុនពេល ដោយពួកគេមិនមានពេលវេលាឲ្យ ស្របតាមតម្រូវការរបស់សាលា និងពួកគេត្រូវការស្វែងរកការងារធ្វើ ដើម្បីមានប្រាក់ចំណូល សម្រាប់ផ្គត់ផ្គង់គ្រួសារ និងការសិក្សារបស់ពួកគេ។*

*ស. ស.៖ ចំណុចខ្លាំងរបស់សិស្សនៅហ្វារលេចចេញពីបទពិសោធន៍ជាក់ស្តែងដ៏អស្ចារ្យ ដែលពួកគេប្រទូក និងផ្លាស់ប្តូរជាមួយអ្នកសិល្បៈអន្តរជាតិ។ ឆ្លងកាត់បទពិសោធន៍ទាំងអស់នេះហើយ ដែលពួកគេបានរៀននូវទស្សនៈនៃការគិតនិងការពិចារណាវែងឆ្ងាយទៅលើសិល្បៈ របៀបបច្ចេកទេសរៀបចំ ឬបង្កើតសិល្បៈ និងសេរីភាពដើម្បីបង្កើតអ្វីៗដែលជាស្នាដៃរបស់ពួកគេផ្ទាល់តែម្តង។ចំណែកចំណុចខ្សោយវិញគឺពួកគេខ្វះការយល់ដឹងនូវអ្វីដែលជាមូលដ្ឋាននៃប្រវត្តិសិល្បៈខ្មែរបុរាណ អាស៊ី ឬអឺរ៉ុប។ ទាំងនេះហើយជាចំណុចសំខាន់បំផុតដែលសិស្សទាំងឡាយត្រូវការបន្ថែម ដើម្បីពង្រីកនូវអត្តសញ្ញាណសិល្បៈរបស់ពួកគេរៀងៗខ្លួន។*

*ត. វ.៖ ចំណុចខ្លាំងរបស់សិស្សនៅហ្វារគឺសិស្សទាំងនោះអាចរស់ដោយខ្លួនឯងបាននិងគេអាចបង្កើតរបៀបផ្ទាល់ខ្លួនក្នុងស្នាដៃសិល្បៈរបស់គេ។ចំណែកចំណុចខ្សោយរបស់ពួកគេវិញគឺពួកគេជម្នះជីវិតដើម្បីរស់ដោយសារស្នាដៃសិល្បៈរបស់ពួកគេ។*

អ្វីទៅជាបញ្ហាប្រឈម ដែលសាលាជំនាញសិល្បៈសូនរូប និងសិល្បៈអនុវត្តន៍របស់ហ្វារពន្លឺសិល្បៈជួបប្រទះបច្ចុប្បន្ន?

*ស. ប.៖ ឧបសគ្គដែលប្រឈមចំពោះមុខរបស់ហ្វារសម្រាប់ផ្នែកសិល្បៈសូនរូបនិងសិល្បៈអនុវត្តន៍ គឺត្រូវបណ្តុះបណ្តាលសមត្ថភាពនិងគុណភាពនៃរបៀបបង្រៀន។*

*ឃ. ជ.៖ យើងជួបប្រទះនូវកង្វះខាតធនធានមនុស្សនៅក្នុងសាលាជំនាញសិល្បៈសូនរូបនិងសិល្បៈអនុវត្តន៍ ព្រោះគ្រូមួយចំនួនពុំទាន់ស៊ាំជាមួយនឹងកម្មវិធីសិក្សាថ្មី ដែលតម្រូវឲ្យមានការបណ្តុះបណ្តាលច្រើន។ សាលាហាក់ដូចជាលុបចោលបទបញ្ញាសិក្សា ឬកម្មវិធីសិក្សាចាស់ខ្លួន ចំពោះសិស្សមិនមានពេលសិក្សាគ្រប់គ្រាន់ ឬពួកគេមកដោយគ្រាន់តែជាការកម្សាន្តនោះ។ ទាំងនេះធ្វើឲ្យចំនួនសិស្សមានការថយចុះពីមួយថ្ងៃទៅមួយថ្ងៃ។បទបញ្ញាសិក្សាថ្មីឬកម្មវិធីសិក្សាថ្មីតម្រូវឲ្យសិស្សមករៀនពេញម៉ោងដូច្នេះសិស្សពុំមានពេលគ្រប់គ្រាន់ការងារខាងក្រៅដើម្បីរកប្រាក់ចំណូលសម្រាប់គ្រួសារដែលបង្ខំឲ្យពួកគេចាកចេញពីសាលា ព្រោះសាលាមិនមានអ្វីផ្គត់ផ្គង់ពួកគេ។*

*ស. ស.៖ វិស័យសិល្បៈសូនរូបនៅហ្វារកំពុងរៀបចំកំណែទម្រង់ឡើងវិញទាំងផ្នែកគរុកោសល្យបង្រៀន និងរបៀបបច្ចេកទេសរបស់ខ្លួន ដើម្បីក្លាយខ្លួនទៅជាសាលាសិល្បៈដ៏ធំជាងគេ និងល្អជាងគេនៅស្រុកខ្មែរ។*

*ត. វ.៖ នៅមានឧបសគ្គខ្វះៗទៀតដែលហ្វារត្រូវដោះស្រាយដូចជាត្រូវបំពេញបន្ថែមផ្នែកសម្ភារៈថ្មីៗនិងត្រូវកែលម្អលក្ខខណ្ឌសិក្សាថ្មី ព្រមទាំងពង្រីកការបណ្តុះបណ្តាលសមត្ថភាពគ្រូបង្រៀនបន្ថែម។*

តើអ្នកមានអារម្មណ៍យ៉ាងណាដែរចំពោះការកើនឡើងនូវចំណាប់អារម្មណ៍របស់អន្តរជាតិមកលើសិល្បៈសហសម័យនៅក្នុងប្រទេសកម្ពុជា ? តើខេត្តបាត់ដំបងមានតួនាទីអ្វីខ្លះនៅក្នុងសិល្បៈសហសម័យកម្ពុជា ?

*ស. ប.៖ ខ្ញុំគិតថាការចាប់អារម្មណ៍នេះផ្តល់នូវឱកាសដ៏ល្អមួយសម្រាប់វិចិត្រករ ឬសិល្បករក្មេងៗជំនាន់ក្រោយ ពីព្រោះពួកគេមានតួនាទីក្នុងការអភិវឌ្ឍន៍និងចែករំលែកទស្សនៈនិងគំនិតរបស់ពួកគេជាមួយពិភពលោក។ ដូចគ្នានេះតួនាទីនៃអ្នកវិចិត្រករឬសិល្បករនៅបាត់ដំបងគឺបង្ហាញអំពីការងាររបស់ពួកគេនិងលើកកម្ពស់ខេត្តនេះឲ្យក្លាយជាកន្លែងប្រមូលផ្តុំនៃសិល្បៈនិងវប្បធម៌មួយដ៏សំខាន់នាពេលខាងមុខ។*

*ឃ. ជ.៖ នេះជាឱកាសមួយសម្រាប់សិល្បៈសហសម័យកម្ពុជា ក្នុងការបោះជំហានទៅក្នុងទីផ្សារអន្តរជាតិ និងជាមធ្យោបាយមួយសម្រាប់សិល្បករត្រូវតែអភិវឌ្ឍនូវអត្តសញ្ញាណ និងជំនាញរបស់ពួកគេ ដើម្បីឈោងចូលទីផ្សារអន្តរជាតិ។ ជាងនេះទៅទៀត វាក៏ឱកាសល្អសម្រាប់ហ្វារពន្លឺសិល្បៈដែរ ដែលអាចទទួលបានសិស្សច្រើនបន្ថែម។ បច្ចុប្បន្នខេត្តបាត់ដំបងមានការលូតលាស់គួរឲ្យកត់សម្គាល់លើវិស័យសិល្បៈសហសម័យ វិចិត្រសាលសហសម័យនិងស្ទូឌីយោសិល្បៈបានកើតឡើងព្រោងព្រាតក្នុងក្រុងបាត់ដំបង។ មន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តបាត់ដំបងមានតួនាទីនិងការងារចម្បងយ៉ាងសំខាន់ក្នុងជួយជម្រុញនិងគាំទ្រនូវការរីកចម្រើននៃកន្លែងសិល្បៈទាំងនោះ និងសម្របសម្រួលឲ្យមានដំណើរការ និងមានការប្រព្រឹត្តទៅនូវព្រឹត្តិការណ៍សិល្បៈក្នុងខេត្តបាត់ដំបង។ ក៏ប៉ុន្តែមន្ទីរនេះត្រូវតែទទួលបានការគាំទ្រក្នុងការសម្រេចចិត្តនានាពីថ្នាក់លើករបស់ខ្លួន។*

*ស. ស.៖ ការវិឌ្ឍន៍ផ្នែកសិល្បៈសហសម័យនៅប្រទេសកម្ពុជាត្រូវបានទទួលការចាប់ អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អ្នកជំនាញផ្នែកសិល្បៈបែបនេះមកពីជុំវិញពិភពលោក។*
*ភាពរីកលូតលាស់ទាំងនេះមានន័យថា ហ្វារត្រូវតែ ៖*

- *រៀបចំបន្ថែមនូវរចនាសម្ព័ន្ធគ្រប់គ្រងទូទៅរបស់ខ្លួន។*
- *ពង្រឹងជំនាញគរុកោសល្យបង្រៀនបុគ្គលិករបស់ខ្លួន។*
- *បញ្ចូលកម្មវិធីសិល្បៈអនុវត្តន៍យ៉ាងហោចណាស់៤ម៉ោងក្នុងមួយសប្តាហ៍ទៅលើប្រវត្តិសិល្បៈពិភពលោក។*
- *បង្កើតអាគារស្នាក់នៅសម្រាប់អ្នកជំនាញសិល្បៈបរទេសនៅហ្វារ ដើម្បីឲ្យសិស្សរបស់ហ្វារមានឱកាសចូលរួមស្រាវជ្រាវ និងអនុវត្តការងារជាក់ស្តែងជាមួយអ្នកជំនាញសិល្បៈទាំងនោះ។*
- *ស្វែងរកដៃគូជាមួយសាកលវិទ្យាល័យអន្តរជាតិផ្សេងៗ។*
- *ជួលអ្នកមានជំនាញច្បាស់ខាងការសរសេរនិងជំនាញដទៃទៀតដែលចាំបាច់ដើម្បីជម្រុញអ្នកសិល្បៈវ័យក្មេងនៅហ្វារឲ្យឈានដល់កម្រិតអន្តរជាតិ និងក្លាយជាអ្នកសិល្បៈអន្តរជាតិ។*
- *បង្កើតកន្លែងមួយសម្រាប់ថែរក្សាមរតកវប្បធម៌ខ្លួនឯង ( គឺរបស់ហ្វារ) ដូចជាសារមន្ទីរនិងបណ្ណសារដ្ឋានតម្កល់សិល្បៈសហសម័យនៅប្រទេសបារាំង។*

- *បង្កើតបណ្ណាល័យដែលអាចឲ្យអ្នកសិល្បៈស្រាវជ្រាវ និងបណ្ដុះបណ្ដាលការសិក្សារបស់ពួកគេដោយខ្លួនឯង។*
- *បែងចែកការសិក្សាសិល្បៈឲ្យដាច់ពីសកម្មភាពសិល្បៈសម្រាប់កំសាន្តផ្សេងៗ។*

*ត. វ.៖ ខ្ញុំមានអារម្មណ៍រីករាយសប្បាយចំពោះការរីកសាយចំណាប់អារម្មណ៍អន្តរជាតិលើវិស័យសិល្បៈសហសម័យរបស់កម្ពុជា ពីព្រោះយើងជាផ្នែកមួយនៃចលនាវិវត្តន៍នេះ។ ខេត្តបាត់ដំបងជាផ្នែក ឬកន្លែងចាំបាច់ដ៏សំខាន់មួយសម្រាប់វិស័យសិល្បៈសហសម័យរបស់កម្ពុជា ដោយសារតែមានសិល្បករ និងវិចិត្រកររស់នៅទីនេះច្រើន និងថែមទាំងមានសាលាបណ្ដុះបណ្ដាលសិល្បៈរបៀបនេះផង។*

នៅពេលដែលអ្នកគិតដល់សិល្បៈ និងប្រទេសកម្ពុជា អ្វីដែលធ្វើឲ្យអ្នកខឹង? អ្វីដែលធ្វើអ្នកសប្បាយ?

*ស. ប.៖ អ្វីដែលធ្វើឲ្យខ្ញុំខឹងសម្បាខ្លាំងនៅពេលដែលខ្ញុំគិតអំពីសិល្បៈនៅក្នុងប្រទេសរបស់ខ្ញុំនោះ គឺខ្ញុំគ្មានសេរីភាពក្នុងការបញ្ចេញអារម្មណ៍ពិតតាមរយៈស្នាដៃសិល្បៈដែលបង្ហាញក្នុងទីសាធារណៈនោះទេ ពីព្រោះកិច្ចការទាំងនេះពុំបានទទួលការយកចិត្តទុកដាក់ពីរដ្ឋាភិបាល ជាពិសេសពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈតែម្ដង។ ប៉ុន្តែអ្វីដែលផ្ដល់ឲ្យខ្ញុំនូវភាពរីករាយនោះ គឺការឃើញភាពរីកលូតលាស់របស់សហគមន៍សិល្បៈនៃខេត្តបាត់ដំបង។ ស្រដៀងគ្នានេះ ខ្ញុំស្រលាញ់ចំណេះដឹងសិល្បៈរបស់ខ្លួនខ្ញុំនិងការចែករំលែកបទពិសោធន៍របស់ខ្ញុំជាមួយនឹងសហគមន៍សិល្បៈ។*

*ឃ. ជ.៖ សិល្បៈនៅក្នុងប្រទេសកម្ពុជា ពុំមានសេរីភាពក្នុងការបញ្ចេញទស្សនៈនិងអារម្មណ៍ពិតបានឡើយ ពោលគឺគ្រប់យ៉ាងស្ថិតក្រោមការត្រួតពិនិត្យ និងត្រូវធ្វើតាមតែចំណុចវិជ្ជមានប៉ុណ្ណោះ។ សិល្បករមិនអាចបញ្ចេញនូវរឿងពិត ដែលផ្ទុយពីគំនិតរបស់ថ្នាក់ដឹកនាំ។ នេះជាអ្វីដែលធ្វើឲ្យខ្ញុំខឹង។ ចំពោះសិល្បៈពួកគេតែងតែមានការប្រកួតប្រជែង ប្រើឧបាយកលដាក់គ្នា និងធ្វើមិនដឹងមិនឮ នូវអ្វីដែលកំពុងកើតឡើង និងមានភាពភ័យព្រួយក្នុងការបញ្ចេញយោបល់។ អ្វីដែលធ្វើឲ្យខ្ញុំសប្បាយចិត្តនោះគឺថា សិល្បៈត្រូវបានទទួលស្គាល់ទាំងលក្ខណៈជាតិផង និងអន្តរជាតិផង ព្រោះតែផលិតផលនៃស្នាដៃសិល្បៈ ការអភិវឌ្ឍសហគមន៍ និងការឈានចូលទៅក្នុងទីផ្សារអន្តរជាតិ។*

*ស. ស.៖ នៅពេលដែលខ្ញុំគិតអំពីសិល្បៈនៅកម្ពុជា ខ្ញុំតែងនឹកខឹងដល់រដ្ឋាភិបាលស្រុកខ្មែរដែលពុំមានសមត្ថភាពគ្រប់គ្រាន់ដើម្បីគាំទ្រដល់វិស័យសិល្បៈ។ ភាពអប់អួរទាំងនេះធ្វើឲ្យខ្ញុំយកមកបង្ហាញតាមការងារសិល្បៈរបស់ខ្ញុំ។*

*ត. វ.៖ អ្វីដែលធ្វើឲ្យខ្ញុំខឹងខ្លាំងនៅពេលដែលខ្ញុំគិតដល់សិល្បៈនៅក្នុងប្រទេសរបស់ខ្ញុំនោះ គឺយើងគ្មានសេរី*

*ភាពគ្រប់គ្រាន់ក្នុងការបញ្ចេញទស្សនៈរបស់ខ្លួន និងបង្ហាញស្នាដៃសិល្បៈនៅទីសាធារណៈឡើយ។ អ្នកខ្លះលើកតម្លៃវិចិត្រករគ្រាន់ជាមធ្យោបាយរកប្រយោជន៍សម្រាប់អាជីវកម្មរបស់របស់ពួកគេប៉ុណ្ណោះ។ ផ្ទុយទៅវិញខ្ញុំមានអារម្មណ៍សប្បាយរីករាយពេលដែលឃើញប្រជាពលរដ្ឋខ្មែរចាប់អារម្មណ៍ទៅលើការតាំងពិព័រណ៍ស្នាដៃសិល្បៈផ្សេងៗ។*

តើអ្នកធ្លាប់សុបិន្តឃើញជម្រុំសាយធូទេ ? អ្វីទៅជាអនុស្សាវរីយ៍ដែលអ្នកបានរក្សាពីជម្រុំសាយធូ ?

*ស. ប.៖ ខ្ញុំតែងតែសុបិន្តឃើញជម្រុំសាយធូ។ អនុស្សាវរីយ៍ល្អបំផុតដក់ជាប់ជាមួយខ្ញុំកាលនៅជម្រុំសាយធូ គឺមិត្តភក្តិរបស់ខ្ញុំ, សាសារបស់ខ្ញុំ, ថ្នាក់គំនូររបស់ខ្ញុំ និងអ្នកជាទីស្រឡាញ់របស់ខ្ញុំ។ ខ្ញុំនឹងពុំងអាចបំភ្លេចបាននូវស្ថានភាពរស់នៅនិងជួរភ្នំដងរែកបានឡើយ។*

*ឃ. ជ.៖ ពិតណាស់ខ្ញុំឧស្សាហ៍សុបិន្តឃើញជម្រុំសាយធូ។ វារំលឹកដល់ខ្ញុំថា ខ្ញុំហាក់ដូចជារស់នៅក្នុងគុក ប៉ុន្តែខ្ញុំចូលចិត្តវា។ ឆ្នាំ២០០៤ ខ្ញុំបានទៅមើលជម្រុំសាយធូនេះម្តងទៀត ដែលជាកន្លែងដែលខ្ញុំធ្លាប់រៀន និងរស់នៅពីមុន។ ទាំងអស់នោះបានរំលឹកខ្ញុំថា ខ្ញុំគួរតែបំភ្លេចអតីតកាលចោល ព្រោះវាគ្រាន់តែកន្លែងស្នាក់នៅបណ្តោះអាសន្នប៉ុណ្ណោះ។ អ្វីមិនអាចបំភ្លេចទាល់តែសោះនោះ គឺពេលវេលាដែលខ្ញុំបានរៀនជាមួយអ្នកគ្រូ* Véronique។ *ព្រោះវាផ្តល់ឲ្យខ្ញុំនូវសេរីភាពក្នុងការបញ្ចេញអារម្មណ៍អំពីអ្វីដែលខ្ញុំរងទុក្ខក្នុងរបបខ្មែរក្រហម និងជីវិតក្នុងមណ្ឌលកុមារកំព្រា, ការទំនាក់ទំនងនៅក្នុងមណ្ឌលកុមារកំព្រានិងសាលារៀន និងមិត្តភក្តិ។*

*ស. ស.៖ សាយធូគឺជាផ្នែកយ៉ាងសំខាន់នៅក្នុងជីវិតខ្ញុំ ហើយជាអ្វីដែលខ្ញុំរក្សាទុកនៅក្នុងការចងចាំរបស់ខ្ញុំ!។ ខ្ញុំជាសមាជិកនៃគ្រួសារសិល្បៈមួយដែលបានបង្កើតឡើងដោយអ្នកគ្រូ* Véronique។

*ត. វ.៖ ពិតប្រាកដណាស់ខ្ញុំតែងតែយល់សុបិន្តឃើញជម្រុំសាយធូខ្ញុំបានរក្សារូបភាពទាំងនោះនៅក្នុងអារម្មណ៍របស់ខ្ញុំ, មិត្តភក្តិកាលពីនៅក្មេងវ័យរបស់ខ្ញុំ, សាលារៀនដ៏ស្រស់ស្អាតរបស់ខ្ញុំ (ថ្វីត្បិតតែការរៀននោះនៅក្រោមដើមឈើក៏ដោយ មុនពេលខ្ញុំមកដល់ជម្រុំជនភៀសខ្លួន), ជម្នះក្នុងជីវិតប្រចាំថ្ងៃ (ហាក់ដូចជាមិនមានអាហារគ្រប់គ្រាន់សម្រាប់ទទួលទានព្រោះខ្ញុំមានសមាជិកគ្រួសារច្រើននាក់)។ ខ្ញុំចាំបានថា*UNBRO *បានផ្តល់ប័ណ្ណបើករបបអាហារសម្រាប់តែមនុស្សស្រីប៉ុណ្ណោះ មិនសម្រាប់មនុស្សប្រុសទេ។ ដោយគ្រួសារខ្ញុំមិនមានមនុស្សស្រីច្រើននោះ ជាហេតុធ្វើឲ្យការរស់នៅមានភាពលំបាកលំបិន។* UNBRO *បានបន្តបែកប័ណ្ណអាហាររៀងរាល់ឆ្នាំ ហេតុដូច្នេះ នៅពេលខ្ញុំទៅទទួលប័ណ្ណអាហារនោះ ខ្ញុំត្រូវតុបតែងខ្លួនជាមនុស្សស្រីដោយយកស្គុតចងព័ទ្ធទាញប្រដាប់ភេទទៅក្រោយ ទុកសក់ទុកឲ្យវែង និងផាត់មុខផាត់មាត់ ព្រោះនៅពេលបែកប័ណ្ណមានអ្នកត្រួតពិនិត្យតើមនុស្សស្រីមែនឬអត់។ វាជារឿងមួយដ៏អាម៉ាស់ក្នុងការធ្វើរឿងបែបនេះសម្រាប់ខ្ញុំ។ ពេលខ្លះឪពុកខ្ញុំនិងខ្ញុំលួចចេញក្រៅរបងជម្រុំដើម្បីរកអាហារបន្ថែម។ ជារឿងប្រឈមនឹងគ្រោះថ្នាក់ខ្លាំង*

## ដំណើររឿងនៃហ្វាពន្លឺសិល្បៈ

*ណាស់ពេលដែលយើងដើរកាត់តំបន់ដែលមានមីននៅពេលយប់។ យើងដើរគេចពីទាហានថៃដែលយាមកាមជម្រុំទាំងយប់ទាំងថ្ងៃ។ សំណួរបានដក់ជាប់នឹងខួរក្បាលរបស់ខ្ញុំជារៀងរហូត ហេតុអ្វីអង្គការសហប្រជាជាតិផ្តល់ប័ណ្ណអាហារសម្រាប់តែមនុស្សស្រី? ការសិក្សាទាំងអស់គឺឥតបង់ថ្លៃនៅជម្រុំសាយធូ។ក្លិននំប៉័ងនៅពេលយើងសម្រាកពីថ្នាក់រៀនគឺនៅតែជាប់ក្នុងចិត្តខ្ញុំ។ ជីវិតរបស់ខ្ញុំបានប្រសើរឡើងនៅពេលដែលខ្ញុំបានទៅរៀនជាមួយអ្នកគ្រូ* Véronique។ *ខ្ញុំបានទិញកង់មួយលើកដំបូងបន្ទាប់ការដេញលក់ស្នាដៃសិល្បៈរបស់ពួកយើងដែលរៀបចំឡើងដោយអ្នកគ្រូ* Véronique។

តើហ្វារពន្លឺសិល្បៈមានន័យអ្វីសម្រាប់អ្នក?

ស. ប.៖ *ហ្វារពន្លឺសិល្បៈគឺជាជីវិតរបស់ខ្ញុំ។*

ឃ. ជ.៖ *ហ្វារពន្លឺសិល្បៈសម្រាប់ខ្ញុំ គឺជាមណ្ឌលអប់រំ និងបណ្តុះបណ្តាលជំនាញសិល្បៈមួយ ដែលជួយដល់ក្មេងដែលងាយរងគ្រោះ, យុវជន និងគ្រួសាររបស់ពួកគេជារៀងរហូត។ ហ្វារជាគ្រួសារមួយ, ហ្វារពុំមែនជារបស់នរណាមួយឡើយ ពោលគឺសម្រាប់យើងទាំងអស់គ្នា។*

ស. ស.៖ *ហ្វារពន្លឺសិល្បៈ ចំពោះខ្ញុំមានន័យថា "ចង្កៀងដ៏ធំមួយដែលបំភ្លឺផ្លូវសម្រាប់នាវាមួយអាចចូលចតដោយសុវត្ថភាព"។ លើសពីនេះ អាចនិយាយម៉្យាងទៀតថា ជាទីកន្លែងសម្រាប់ដឹកនាំបំភ្លឺដល់អ្នកដែលស្រឡាញ់វិស័យសិល្បៈឲ្យក្លាយខ្លួនទៅជាបុគ្គលដែលមានប្រយោជន៍សម្រាប់សង្គមជាតិ។*

ត. វ.៖ *សម្រាប់ខ្ញុំហ្វារពន្លឺសិល្បៈគឺជាផ្នែកមួយនៃជីវិតរបស់ខ្ញុំ។ វាជាដំណើរផ្សងព្រេងដ៏វែងឆ្ងាយមួយ និងនៅតែជាការផ្សងព្រេងមួយទៅអនាគតទៀត។ ជីវិតរបស់ខ្ញុំបានផ្លាស់ប្តូររៀងរាល់ថ្ងៃតាមរយៈហ្វារពន្លឺសិល្បៈ។ មិនមែនតែជីវិតខ្ញុំម្នាក់តែប៉ុណ្ណោះទេគឺសម្រាប់ក្មេងៗនិងយុវវ័យដ៏ទៃទៀតដែលកំពុងរៀននៅទីនេះ។វាមានកន្លែងមួយដែលពិសេសប្លែកគេនៅស្រុកខ្មែរ ដែលប្រើសិល្បៈសម្រាប់ជាមធ្យោបាយជួយក្មេងៗដើម្បីដោះស្រាយ ឬព្យាបាលជំងឺសតិអារម្មណ៍ដោយសារសង្គ្រាមនោះ។ លើសពីនេះទៅទៀត កម្មវិធីសិក្សាចម្រុះជំនាញរបស់ហ្វារពន្លឺសិល្បៈបានផ្តល់ដល់ក្មេងៗនូវទស្សនៈវិស័យនិងជំនាញពិតប្រាកដជាច្រើនសម្រាប់ការចិញ្ចឹមជីវិតដោយយកសិល្បៈជាយាន។ ភាគច្រើនអ្នកដែលមករៀនសូត្រនៅទីនេះគឺចេញពីប្រភព អ្នកក្រីក្រតោកយ៉ាកក្នុងជីវភាពរបស់គេ។ការអប់រំគឺផ្តោតទៅលើរបៀបគិតនិងពិចារណាដោយខ្លួនឯងនិងរស់នៅដោយសុខដុម។ ថ្នាក់ទាំងនោះផ្តល់នូវជំនាញជាច្រើនដូចជា ល្ខោន, សៀក, តន្ត្រី និងកម្រងជំនាញសិល្បៈដ៏ទៀត។អ្វីដែលសំខាន់នោះគឺ ហ្វារពន្លឺសិល្បៈបានបង្កើតឡើងដោយខ្មែរដែលបានរៀនសូត្រសាលាសិល្បៈក្នុងជម្រុំជនភៀសខ្លួនសាយធូ ដែលសិល្បៈនោះជាមធ្យោបាយមួយសម្រាប់សម្រាក់ការព្យាបាលរបួសផ្លូវចិត្ត។*

តើអ្នកនៅតែបន្តការងារផ្នែកសិល្បៈឬទេ? ហេតុអ្វី?

*ស. ប.៖ ខ្ញុំតែងតែផ្សាភ្ជាប់ខ្លួនខ្ញុំនិងសិល្បៈ ពីព្រោះវាជាផ្នែកមួយនៃជីវិតរបស់ខ្ញុំ។ ខ្ញុំគិតថា វាជាផ្នែកមួយនៃទស្សនវិទ្យា និងភាពចាំបាច់នៃវប្បធម៌ចំពោះការរីកលូតលាស់គំនិតប្រាជ្ញារបស់មនុស្សនិងបង្កើនចំណូលសម្រាប់ជីវភាពផង។*

*ឃ. ជ.៖ ពិតណាស់ ខ្ញុំនៅតែធ្វើការងារស្និតជាមួយសិល្បៈ ព្រោះខ្ញុំស្គាល់ពីសារសំខាន់ និងប្រយោជន៍នៃសិល្បៈ និងជាព្រលឹងនិងចក្ខុវិស័យរបស់ហ្វារពន្លឺសិល្បៈ ដែលប្រើប្រាស់សិល្បៈជាឧបករណ៍សម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងការផ្លាស់ប្តូរសង្គម។ ហើយខ្ញុំក៏មានបំណងបន្តនូវអ្វីដែលខ្ញុំបានសិក្សារៀនសូត្រ និងរក្សាវិស័យសិល្បៈរហូតទៅដល់ទីបញ្ចប់។*

*ស. ស.៖ ខ្ញុំនៅតែបន្តបង្កើតសិល្បៈដោយការស្រឡាញ់ ខឹង និងដោយទស្សនៈរិះគន់។*

*ត. វ.៖ពិតហើយខ្ញុំនៅតែធ្វើការលើសិល្បៈព្រោះវាជាផ្នែកមួយនៃជីវិតរបស់ខ្ញុំជាពិសេសខ្ញុំចូលចិត្តវា។សិល្បៈជាឱកាសមួយដែលអាចខ្ញុំបញ្ចេញនូវរាល់អារម្មណ៍របស់ខ្ញុំ, អ្វីដែលខ្ញុំគិត, អ្វីដែលខ្ញុំស្រឡាញ់ ឬស្អប់, អ្វីដែលខ្ញុំចង់ផ្លាស់ប្តូរ, អ្វីដែលខ្ញុំចង់បានទៅអនាគតនិងពីអតីតកាល និងអ្វីៗផ្សេងទៀតដែលនៅរស់រវីកជុំវិញយើង។ វាគឺផ្នែកមួយនៃមនុស្ស ដើម្បីប៉ង់ប្រាថ្នានិងបំពេញតម្រូវការទៅតាមការបង្ហាញនូវអ្វីៗទាំងនោះ។បើសិនពុំមានសិល្បៈហាក់ដូចជារស់នៅក្នុងពិភពលោកមួយដែលមានតែពីរពណ៌គឺសនិងខ្មៅតែនៅពេលមានពណ៌ចម្រុះវិញ គឺជាការជ្រើសរើសមួយទៀត។*